សារព័ត៌មាន ខ្មែរផុស ស.រ.អា
Free Copies
Email:Khmerpostusa@gmail.com
www.khmerpostusa.com
KhmerPost USA
Vol. 15. Issue 368, Dec 19, 2024 | Direct: 978-656-8141
Lowell - Lynn - Revere - MA * Providence - Cranston - RI

# អន្តរកាលនៃអាមេរិកដ៏ជ្រួលច្របល់ មុនពេល លោក ត្រាំ ចូលកាន់អំណាច

អឺរ៉ុប ថ្ងៃទី៥ធ្នូ ២០២៤

នៅជាង៥០ថ្ងៃមុនប្រធានាធិបតីថ្មី ឌណល ត្រាំ ចូលកាន់អំណាច មានការជ្រើសរើសវរជនប្រតិបត្តិ មកកាន់មុខដំណែងជារដ្ឋមន្ត្រីនានា ដើម្បីអនុវត្តន៍នយោបាយ«ម៉ាគ្គា MAGA Make American Great Again»សម្រាប់អាណត្តិថ្មីឆ្នាំ២០២៥ នោះ។ នៅអាណត្តិលោក ត្រាំ ថ្មីនោះ ក៏ពុំមានលក្ខណៈដូចពីអាណត្តិមុនៗទេ អ្វីដែលគេដឹង តាមសេចក្តីថ្លែងការគឺ ក្តីបារម្ភគួរឲ្យខ្លាចទៅវិញ។

ទោសលោកត្រាំប្រមាណ៨០ករណីបានត្រូវលើកលែងដោយតុលាការជាន់ខ្ពស់សម្រេចថា«គ្មានទោសដោយសារកំហុសកើតនៅក្នុងភារៈកិច្ចរបស់ឌណល

សូមអានទំព័រទី១០



JD Vanse vice President Elect & Donald Trump President elect of USA

## ពលរដ្ឋប្រទេសស៊ីរីត់សង្គ្រាមស៊ីវិលរហូតដល់ចុងបញ្ចប់




សូមអានអត្ថបទទាំងស្រុងទំព័រទី១៤

## ចលនា KMD ប្តេជ្ញាតស៊ូ ជាមួយពលរដ្ឋខ្មែររហូតដល់ សិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋ ត្រូវបានស្តារឡើងវិញ


ចលនាខ្មែរដើម្បីប្រជាធិបតេយ្យ
(Khmer Movement For Democracy

តទៅទំព័រទី០៤

## មុខមាត់សង្គ្រាមពិភពលោក ពេលអន្តរកាល មុនលោក ត្រាំ ឡើងកាន់អំណាច


លោក ប៊ិនចាមិន មេត្តាញ៉ាហ៊ូ

តទៅទំព័រទី០៧

# ហេតុអ្វីក៏ កាម៉ាឡា ហារីស ចាញ់ឆ្នោត ឌណាល ត្រាំ

ដោយៈខ្មែរប៉ុស្តិ៍ ស.រ.អា

ក្នុងពេលដែលឌណាលត្រាំ រវល់ជ្រើសរើសគណរដ្ឋមន្ត្រីរបស់លោក សម្រាប់អាណត្តិថ្មី ពលរដ្ឋអាមេរិកាំងជាច្រើនមានចម្ងល់ថា«ហេតុយ៉ាងណាបានជាលោកស្រីអនុប្រធានាធិបតី កាម៉ាឡា ចាញ់ឆ្នោត លោកអតីតប្រធានាធិបតី ត្រាំ


ប្រធានាធិបតីជាប់ឆ្នោត២០២៤ ឌណាល ត្រាំ


អនុប្រធានាធិបតីណ កាម៉ាឡា ហារីស

ទៅបាន?»

| Donald Trump | Kamala Harris |
| --- | --- |
| 49.9% of popular vote | 48.3% of popular vote |
| (76,868,549 votes) | (74,333,382 vote) |
| 312 Delegues Republican | 226 delegues Democrat |

កាសែត ដឹញូយ៉កថាម បានតាំងសំនួរជាច្រើនដល់ប្រជាពលរដ្ឋ ក្រីក្រ ឬនិយោជិកដែលមានប្រាក់ខែតិច បានទទួលចម្លើយគួរឲ្យយល់បាន ពីលទ្ធផលនៃសម្លេងឆ្នោត ក្រោយពិបោះឆ្នោតរួច ដូចតទៅនេះថា «យើងមានការខកចិត្តពីការគ្រប់គ្រងរបស់គណបក្សប្រជាធិបតេយ្យ ដែលមិនបានទប់តម្លៃទំនិញមិនឲ្យឡើង...» មានខ្លះទៀតថា«ពួកប្រជាធិបតេយ្យ បានតែសន្យា តែធ្វើមិនបាន» ខ្លះទៀតនោះថា«ពួកយើងមិនខ្វល់នឹងជម្លោះរវាងគណបក្សសាធារណរដ្ឋ នឹងគណបក្សប្រជាធិបតេយ្យទេ តែគេត្រូវតែជ្រើសយក ឌណាល ត្រាំ ដើម្បីសេដ្ឋកិច្ចប្រសើររបស់ពួកយើង...»ហើយខ្លះទៀតថា«យើងក៏មិនខ្វល់ពិសង្គ្រាមនៅពីភពលោកណានោះទេ តែត្រាំអាចបញ្ចប់សង្គ្រាមបាន ហើយបញ្ឈប់ចំណាយឥតប្រយោជន៍...»។

គណបក្សប្រជាធិបតេយ្យ ខាង កាម៉ាឡា ហារីស តែងតែទទួលការគាំទ្រដោយប្រជាពលរដ្ឋក្រីក្រ នឹងអ្នកមានចំណូលតិច ជាដ៏រាប ដែលធ្វើឲ្យការស្ទង់មតិបានឲ្យ កាម៉ាឡា បានឈ្នះ៣%, ប៉ុន្តែស្រាប់តែពេលបោះឆ្នោតមកដល់ភ្លាមប្រជាពលរដ្ឋទាំងនោះ មានក្រុមជនជាតិភាគតិច មានស្បែកខ្មៅ ស្បានីស ឬ អាស៊ីអាមេរីកាំង ក៏បានប្រែប្រួលចិត្ត នាំគ្នាយ៉ាងច្រើន ទៅបោះឆ្នោតឲ្យ ឌណាល ត្រាំ ទៅវិញ។ ទាំងនោះហើយដែលនាំឲ្យ មតិនៅមុនពេលបោះឆ្នោត គេគិតថាក្រុមជនជាតិភាគតិច នឹងក្រុមប្រជាជនក្រីក្រ នឹងបោះឆ្នោតឲ្យ«កាម៉ាឡា», ប៉ុន្តែនោះជាការភន្តច្រឡំសោះ ដែលសម្រាប់ថ្ងៃបោះឆ្នោត អ្នកទាំងនោះ បែរជាជឿសម្ដីទ្រគោះបស់បោករបស់«ឌណាល ត្រាំ»ថាជាមនុស្សដែលហ៊ានធ្វើឲ្យ«ជិវភាពនៅអាមេរីកប្រសើរឡើងបាន» នោះហើយដែលធ្វើឲ្យសន្លឹកឆ្នោត ត្រាំ ឡើងឈ្នះបានប្រមាណជាង ២លានសម្លេង តែប៉ុណ្ណោះ គឺជាសម្លេងបោះឆ្នោតប្រវត្តិសាស្ត្រថ្មីដ៏ប្រកិតគ្នាជាទិបំផុត ៕



ទំនិញឡើងថ្លៃ ជាបុព្វហេតុចម្បង ធ្វើឲ្យគេជនក្រីក្រ ជឿថា ឌណាល ត្រាំ ពូកែរជាង កាម៉ាឡា ហារីស

COMMUNITY TEAMWORK

Building Communities
Changing Lives

People with disabilities are entitled to reasonable accommodations or modifications that allow them to fully enjoy their housing. Learn more and get help requesting accommodations or modifications from a housing provide by contacting the Community Teamwork Fair Housing program at 978-654-5637 or fairhousing@commteam.org. Any opinions or recommendations expressed in this message are those of the author(s) and do not necessarily reflect the views of the Department of Housing and Urban Development.

ជនពិការមានសិទ្ធិទទួលបានកន្លែងស្នាក់នៅសមហេតុផល ឬការកែប្រែដែលអនុញ្ញាតឱ្យពួកគេទទួលបានលំនៅដ្ឋានពេញលេញ។ ស្វែងយល់បន្ថែមនិងទទួលបានជំនួយក្នុងការស្នើសុំការស្នាក់នៅ ឬការកែប្រែពីលំនៅដ្ឋាន ដែលផ្តល់ដោយទាក់ទងកម្មវិធី Community Teamwork Fair Housing តាមរយៈលេខ 978-654-5637 ឬ fairhousing@commteam.org។ មតិ ឬអនុសាសន៍ទាំងឡាយដែលបានបង្ហាញនៅក្នុងសារនេះគឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់នាយកដ្ឋានលំនៅដ្ឋាននិងអភិវឌ្ឍន៍ទីក្រុងនោះទេ។

# ថ្ងៃទី២៦វិច្ឆិកា២០២៤មានអ្វីគ្រោះកាចអ្វី កើតឡើងចំពោះលោក ត្រាំ?

ថ្ងៃទី២១/១២/២៤ នៅថ្ងៃទី២៦ខាងមុខជាថ្ងៃដែលលោកប្រធានាធិបតីជាប់ឆ្នោត ឌណាល ត្រាំ ត្រូវឡើងតុលាការជាថ្មីម្តងទៀត ដើម្បីទទួលការកាត់ទោស ពី«តុលាការក្រុងនូយ៉ក» ពីបទក្លែងបន្លំឯកសារពន្ធដារចំនួន៣៤ករណី ។ ដោយសារតែការជាប់ឆ្នោតជាប្រធានាធិបតីលោក ត្រាំ អាចរកបាននូវមេធាវីខ្លាំងៗថែមទៀតមកបន្តរក្តីដែលបានកាត់សេចក្តីរួចហើយ ថា«មានកំហុស»តែពន្យាពេល«មិនទាន់ដាក់ចំនួនទោស»។ នេះជាប្រវត្តិសាស្រ្តនៃសហរដ្ឋដែលមាន«ប្រធានាធិបតីជាប់ឆ្នោត ឡើងកាន់អំណាច ដោយមានទោសជាប់ខ្លួន»។



ប្រធានាធិបតីជាប់ឆ្នោត២០២៤ ឌណាល ត្រាំ

សហរដ្ឋអាមេរីកធ្លាប់ល្បីល្បាញពី«ស្ថាប័នឯករាជ្យរបស់តុលាការ» តែពេលនេះថៅកែកាស៊ីណូ ឌណាល ត្រាំ ក៏ល្បីល្បាញខាងល្បិចនៃអាមេរីក«ផ្លូវវៀចវេរ»កំពុងតែស្វែងរក«ការលើកលែងទោស»ឬក៏«ពន្យាពេលដាក់ទោស»ឲ្យទៅដល់ក្រោយពេលចូលកាន់អំណាចនៅថ្ងៃទី២០មករា២០២៥ខាងមុខ ដើម្បីឲ្យអាចប្រើអំណាចជាប្រធានាធិបតីពេញសិទ្ធទៅ«លើកលែងទោសខ្លួនឯង»។ លោក ត្រាំ ធ្លាប់ទទួលការអនុគ្រោះពីតុលាការកំពូល ដែលមានចៅក្រមភាគច្រើន មកពីគណបក្សសាធារណរដ្ឋម្តងរួចហើយ តើករណីនេះនឹងកើតឡើងម្តងទៀតឬយ៉ាងណា? យើងចាំមើលនៅ៣ថ្ងៃទៀត ។

Donald Trump′s sentencing on 34 felony counts related to his 2016 hush money scheme has been put on indefinite hiatus, a judge ruled on Friday.

Manhattan Judge Juan Merchan agreed to a request from both parties to cancel the sentencing, which had been scheduled for November 26.

លោក ត្រាំ បានទទួល «ការពន្យាពេលដាក់ទោសដោយគ្មានកំណត់» ពីចៅក្រម ជូអាន មែកិន កាលពីថ្ងៃសុក្រទី២៣រួចហើយ។ ទាំងចៅក្រម នឹងក្រុមកូនក្តី បានព្រមព្រាងគ្នាឲ្យធ្វើសំណើរសម្រាប់«លើកលែងទោស»នៅមុនពេលឡើងកាន់អំណាច៕

AccuCare
Home Care Agency
ភ្នាក់ងារថែទាំអ្នកជំងឺតាមផ្ទះ
Group Adults Foster Care Program
កម្មវិធីថែទាំមនុស្សពេញវ័យ
144 Merrimack Street • Suite 404
Lowell, MA 01852 • 617-783-7177



Open for enrollment.
Persons with disability and chronic illnesses at no cost to patients.
We provide an individual care plan developed by a registered nurse and case manager.
Service plan includes medication management, personal care service at home, a Nurse and Case Manager monitoring ongoing needs.
Patient must have Masshealth Standard to qualify.
We accept United, Senior Whole Health, Fallon and Commonwealth Care Alliance.

បើកទទួលចុះឈ្មោះ
ជនមានពិការភាព និងអ្នកជំងឺរ៉ាំរ៉ៃ ដោយឥតគិតថ្លៃ។
យើងផ្តល់ផែនការថែទាំអ្នកជំងឺជាបុគ្គលដោយគិលានុបដ្ឋាយិកាដែលមានចុះបញ្ជីត្រឹមត្រូវ និងគ្រូពេទ្យគ្រប់គ្រងអ្នកជំងឺ។
ផែនការសេវាកម្មរួមមាន ការគ្រប់គ្រងឪសថ សេវាថែទាំដោយផ្ទាល់តាមផ្ទះ គិលានុបដ្ឋាយិកា
និងគ្រូពេទ្យគ្រប់គ្រងអ្នកជំងឺពិនិត្យតាមដានជាប្រចាំតាមតម្រូវការ។
ដើម្បីមានលក្ខណៈគ្រប់គ្រាន់ អ្នកជំងឺត្រូវតែមាន Masshealth Standard ។
យើងទទួល United, Senior Whole Health, Fallon
និង Commonwealth Care Alliance ។

# សង្គ្រាមនៅអ៊ូក្រែនអាចនឹងត្រូវបញ្ចប់ មុនពេលត្រាំចូលកាន់អំណាច

អឺរ៉ុប ថ្ងៃទី៣០វិច្ឆិកា២០២៤

ប្រធានាធិបតីជាប់ឆ្នោត ឌណាល ត្រាំ នៅពេលឃោសនាបោះឆ្នោត បាននិយាយថា«លោកអាចនឹងធ្វើឲ្យសង្គ្រាមអ៊ូក្រែន បញ្ចប់ទៅបាន មុនពេលលោកចូលកាន់ដំណែងថ្ងៃទី២០មករា២០២៥ ខាងមុខ»។ ដូច្នេះនៅមុន២ខែទៀតនោះ តើសង្គ្រាមនោះ អាចនឹងចប់បែបណាទៅ? តើទៅរួចដែរឬទេ បើអ៊ូក្រែនពុំព្រមចុះចាញ់នោះ?

គេដឹងទៀតថា«បើមានព្រឹត្តិការដូចនោះកើតឡើងមែនរួចនោះ គឺ ពូទីន ជាអ្នកចំណេញ ប៉ុន្តែតើ ជេឡិនស្គី សុខចិត្តដែរឬទេ?»។ ពូទីន បានបាញ់គ្រាប់ប្លោង ស្រោចមកតំបន់ខាងកើតអ៊ូក្រែន ជាមួយនឹងទ័ពប្រមាណ១០ម៉ឺននាក់មានទាំងទ័ពកូរ៉េខាងជើងប្រមាណ១ម៉ឺននាក់រួមកម្លាំងប្រយុទ្ធទៀតផង,ជាមួយគ្នា




នោះ ជំនួយយោធាទៅអ៊ូក្រែនក៏អាចកាត់ផ្តាច់ ដោយ ឌណាល ត្រាំ ទៀត។ ដោយឃើញថា អាមេរីកឆ្នាំ២០២៥ អាចនឹងផ្តាច់ជំនួយយោធាចាំបាច់ទៅអ៊ូក្រែន លោក ជេឡិនស្គី ក៏ប្រញាប់ចង់បញ្ចប់ទំនាស់ ដោយថ្លែងកាលពីថ្ងៃសៅរ៍






សង្គ្រាមអ៊ុយក្រែនរកកលនឹងឈប់ដោយប្រទេសរ៉ូស្ស៊ីមានឱនភាពសេដ្ឋកិច្ច និងអ៊ុយក្រែនសង្ស៊ឹមតែលើកម្លាំងលោកសេរី

ទី២៩វិច្ឆិកានេះថា«សុខចិត្តបោះបង់តំបន់ខាងកើតអ៊ូក្រែន ជាបណ្តោះអាសន្ន ប៉ុន្តែ...ទាល់តែអង្គការយោធាអឺរ៉ុបគឺអូតង់ សុខចិត្តចូលមករក្សាសន្តិភាពនៅផ្នែកអ៊ូក្រែនដែលនៅសល់ ជាមុនសិន» នេះគឺជាដំណឹងនៃសម្បទានដ៏ធំមួយ ឲ្យទៅរុស្ស៊ី នឹងដែលជាបំណងរបស់ពូទីន ដើម្បីបញ្ចប់ការឈប់បាញ់គ្នា តាំងតែពីដំបូងនោះផងដែរ... ប៉ុន្តែនៅមានចំណុចមួយទៀតដែលរំខានលោក ពូទីន គឺ«មិនចង់ឲ្យអ៊ូក្រែន ចូលជាសមាជិករបស់អូតង់ទេ»។

អ្នកសង្កេតការយល់ថា ទាំងរុស្ស៊ី នឹង ទាំងអ៊ូក្រែន ពុំអាចបន្តសង្គ្រាមបានយូរទេ ដោយ ១ រុស្ស៊ីមានឱនភាពថវិការផង នឹងគ្មានទាហ៊ានជំនាញ សម្រាប់វាយលុកគ្រប់គ្រាន់ផង, រីឯទី ២ ខាងអ៊ូក្រែនវិញ ក៏សង្ឃឹមតែទៅលើអាមេរីកាំង នឹងអឺរ៉ុបទាំងស្រុងដែរ ដូច្នេះអ្នកទាំង២ ត្រូវរកច្រកបញ្ចប់សង្គ្រាម ដោយមិនឲ្យបាក់មុខតែរៀងៗខ្លួន។

សម្រាប់លោក ជេឡិនស្គីវិញលោកបង្ហាញថា«បានដឹកនាំប្រទេសអ៊ូក្រែនចេញពីរបស់កុម្មុយនិស្ត ប្រកបដោយជោគជ័យ នឹងការជឿជាក់យ៉ាងរឹងមាំរួចហើយ» ដូច្នេះបើទោះជាមានការលះបង់ផ្នែកខ្លះនៃប្រទេសខ្លួនក្តី ក៏ប្រជាជាតិអ៊ូក្រែន អាចនឹងយល់ពីវត្ថុបំណង បញ្ចប់សង្គ្រាមពេលនេះបានប្រសើ ជាជាងនៅរង់ចាំឲ្យអាមេរីកកាត់ផ្តាច់ជំនួយយោធា ទើបរកមធ្យោបាយដោះស្រាយ ជាបន្តរ ដែលអាចនឹងបាត់បង់«អ៊ូក្រែងទាំងមូល»ផង ក៏មិនដឹង៕

# ចលនា KMD ប្តេជ្ញាតស៊ូជាមួយពលរដ្ឋខ្មែររហូតដល់សិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋត្រូវបានស្តារឡើងវិញ

ចលនាខ្មែរដើម្បីប្រជាធិបតេយ្យ (Khmer Movement For Democracy (KMD)) ប្តេជ្ញាតស៊ូជាមួយប្រជាពលរដ្ឋខ្មែររហូតដល់សិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋគ្រប់រូបត្រូវបានស្តារឡើងវិញរួចផុតពីរបបជិះជាន់របស់គ្រួសារត្រកូលហ៊ុន។



ចលនាខ្មែរដើម្បីប្រជាធិបតេយ្យ (KMD) ចេញសេចក្តីថ្លែងការណ៍សម្រាប់ខួបលើកទី៧៦ នៃទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ធ្នូ នៅថ្ងៃទី១១ ធ្នូ នេះថា សិទ្ធិមនុស្ស និងសង្គមប្រជាធិបតេយ្យ ដែលធានាដោយរដ្ឋធម្មនុញ្ញ គ្រាន់តែជាការចងចាំដ៏សែនឆ្ងាយសម្រាប់ពលរដ្ឋកម្ពុជាប៉ុណ្ណោះក្នុងពេលនេះ ដោយសារការគាបសង្កត់ដ៏ឃោរឃៅពីរបបដឹកនាំត្រកូលហ៊ុន។

ប្រភពដដែលលើកឡើងថា ការមិនអើពើសិទ្ធិសេរីភាពរបស់មនុស្ស និងច្បាប់អន្តរជាតិក្នុងការការពារសិទ្ធិជាសកល បានគូសបញ្ជាក់យ៉ាងច្បាស់អំពីលក្ខណៈផ្តាច់ការនៃរបបដឹកនាំរបស់គ្រួសារមួយនេះ ខណៈតុលាការដែល

តទៅទំព័រទី០៨




# គេហដ្ឋានដែលសន្សំសំចៃថាមពល ជិតល្មមនឹងសម្រេចបាន។

ធ្វើឱ្យប្រសើរឡើងនូវផាសុកភាព និងប្រសិទ្ធភាពនៃគេហដ្ឋានរបស់អ្នកជាមួយនឹងការវាយតម្លៃថាមពលក្នុងផ្ទះដោយមិនគិតថ្លៃ។ វាគ្រាន់តែជាវិធីមួយក្នុងចំណោមវិធីជាច្រើនដែលយើងនៅទីនេះ ដើម្បីវាយតម្លៃផ្ទះរបស់អ្នក។

**នេះជារបៀបដំណើរការ៖**

- អ្នកឯកទេសថាមពលនឹងស្វែងរកកន្លែងដែលគេហដ្ឋានរបស់អ្នកអាចនឹងបាត់បង់ថាមពល ជាពិសេសក្នុងអំឡុងពេលខែក្តៅ និងត្រជាក់ខ្លាំង។
- អ្នកឯកទេសអាចដំឡើងឧបករណ៍សន្សំសំចៃថាមពលដោយមិនគិតថ្លៃ និងផ្តល់នូវការកែលម្អប្រព័ន្ធសន្សំសំចៃថាមពលក្នុងផ្ទះ ដូចជាការបញ្ចុះតម្លៃ 75-100% លើការដំឡើងអ៊ីសូឡង់ និងការបិទភ្ជិតខ្យល់ចេញដោយមិនគិតថ្លៃ។
- ពួកគេថែមទាំងអាចពិភាក្សាអំពីការបញ្ចុះតម្លៃ និងការលើកទឹកចិត្តចំពោះឧបករណ៍ដែលមានប្រសិទ្ធភាពថាមពល។

**99% នៃអតិថិជនដែលបានបញ្ចប់ការវាយតម្លៃថាមពលក្នុងផ្ទះនឹងណែនាំវាទៅមិត្តភក្តិ ឬសមាជិកគ្រួសារ។**

nationalgrid

**មោទនភាពជាអ្នកឧបត្ថម្ភរបស់**

mass save

**កំណត់ពេលវាយតម្លៃថាមពលក្នុងផ្ទះរបស់អ្នកនៅថ្ងៃនេះ។**
**ចូលទៅកាន់គេហទំព័រ**
**ngrid.com/assessment**
**ឬទូរសព្ទទៅលេខ**
**1-866-527-SAVE (7283)**

**PRINT READERSHIP**
*50,000 Monthly / 600,000 Annually*
*Plus additional exposure in our online editions at khmerpostusa.com*

**ONLINE EDITIONS AVAILABLE AT KHMERPOSTUSA.COM**

# 2025 PRINTING SCHEDULES

## EFFECTIVE JANUARY 1, 2025

## ADVERTISING RATES AND SIZES

*All ads are printed in Full Color*

**Ad Size (WxH)**

| | |
|---|---|
| **Full Inside** (10" wide x 13" tall) | $ 552.00 |
| **1/2** (10" wide x 6.5" tall) | 375.00 |
| **1/4** (5" wide x 6.5" tall) | 192.00 |
| **1/8** (5" wide x 3.25" tall) | 108.00 |
| **Business Card** (3.5" wide x 2" tall) | 60.00 |
| **Full Back Page** (10" wide x 13" tall) | $ 1000.00 |
| **Front Page 1/2** (10" wide x 6.5" tall) | 1000.00 |
| **Front Page 1/4** (5" wide x 6.5" tall) | 620.00 |
| **Front Page 1/8** (5" wide x 3.25" tall) | 350.00 |
| **Front Page Business Card** (3.5" wide x 2" tall) | 200.00 |

Your ad is also published in our online editions of the newspaper at khmerpostusa.com




## 2025 PRINTING DATES

***Advertising deadlines are 5 business days prior to printing date.***

| | | |
|---|---|---|
| January | 15 | Wednesday |
| February | 9 | Sunday |
| March | 3 | Monday |
| April | 1 | Tuesday |
| May | 1 | Thursday |
| June | 1 | Sunday |
| July | 1 | Tuesday |
| August | 1 | Friday |
| September | 1 | Monday |
| October | 1 | Wednesday |
| November | 1 | Saturday |
| December | 1 | Monday |

## MONTHLY DISTRIBUTION

***70+ Locations in Lowell, MA • 7,000 copies***
***25 Locations in Lynn & Revere, MA • 1,000 copies***
***25 Locations in Providence & Cranston, RI • 2,000 copies***
***Additional distribution online***

***Khmer Post USA Distribution Locations Include:***

*Households • Markets • Retail Businesses*
*Restaurants • Office Buildings • Government Offices*
*Chamber of Commerce • Buddhist Temple*
*Laundromats • And Much More*

## CONTACT INFO

**Khmer Post USA • P.O. Box 8848 • Lowell, MA 01853**
**Tel: 978.677.7163 • Fax: 978.677.7092**
**Email: khmerpostusa@gmail.com**
**www.khmerpostusa.com**

*Khmer Post USA is a proud member of New England Press & Newspaper Association and Greater Merrimack Valley Convention and Visitors Bureau*

Follow us @KhmerPostUSA

Subscribe @KhmerPostUSA

Follow us @KhmerPostUSA

# មុខមាត់សង្គ្រាមពិភពលោកពេលអន្តរកាល

សហរដ្ឋអាមេរិកធ្លាប់មានឥទ្ធិពលលើពិភពលោកយ៉ាងខ្លាំងក្លា នៅចុងឆ្នាំ២០២៤នេះ លោក ឌណាល ត្រាំ ត្រៀមខ្លួននឹងឡើងកាន់អំណាចនៅសហរដ្ឋអាមេរិកនេះ ប៉ុន្តែលោក ត្រាំ ពុំមាននយោបាយក្នុង និងក្រៅប្រទេស ដូចប្រធានាធិបតីមុនៗនោះទេ ដែលជាហេតុធ្វើឲ្យអ្នកសង្កេតការណ៍នានាធ្វើការវិភាគមិនត្រឹមត្រូវ ស្ទើរតែគ្រប់កន្លែង នៅក្នុងអត្ថបទខាងក្រោមនេះ យើងនឹងបង្ហាញពីមុខមាត់ពីភពលោកនៅឆ្នាំ២០២៥ ដែលត្រៀមនឹងផ្លាស់ប្តូរនៅចាប់តាំងពីខែមករាឡើងទៅ។

ដោយៈខ្មែរប៉ុស្តិ៍ស.រ.អា

ពិភពលោកកំពុងត្រៀមខ្លួន ទប់ទល់នឹងការផ្លាស់ប្តូរ ស្ទើរតែផ្ទុយស្រឡះ នៅពេល ឌណាល ត្រាំ ឡើងកាន់អំណាចជាប្រធានាធិបតីនៃសហរដ្ឋអាមេរិក ដែលមានឥទ្ធិពលដ៏ធំធេង លើសន្តិភាព នឹងសេដ្ឋកិច្ចពិភពលោកនៅថ្ងៃទី២០ខែមករា ឆ្នាំ២០២៥ បន្តទៅ៤ឆ្នាំខាងមុខ។ បើតាមសម្តីលោក ត្រាំ គឺសង្គ្រាមនៅអ៊ុយក្រែនហើយនឹងនៅអ៊ីស្រាអែល នឹងត្រូវបញ្ចប់ឲ្យបានឆាប់។

***សង្គ្រាមអ៊ីស្រាអែលនឹងហាម៉ាសៈ

ប្រទេស៤នៅមជ្ឈឹមបូព៌ា ដែលភ្លើងសង្គ្រាមកំពុងតែឆាបឆេះគឺអ៊ីស្រាអែល ប្រយុទ្ធទល់នឹង ប្រទេសមូស្លីម ប៉ាឡេស្ទីន(គ្រប់គ្រងដោយក្រុមហាម៉ាស់)ប្រទេសលីបង់(ភេរវករប្រយុទ្ធជួរមុខ) នឹង ប្រទេសអ៊ីរ៉ង់(ជាមេខ្លោងនៃក្រុមភេរវករ)។ អ៊ីស្រាអែល បន្តការវាយប្រហារសងសឹក ទៅលើប្រទេសមូស្លីមទាំង៣ប្រទេសនោះ ដោយយុទ្ធសាស្ត្រយោធាខ្លាំងខ្លា ដើម្បីកំទេចក្រុមហាម៉ាស់ នៅគ្រប់កន្លែងដែលហាម៉ាស់លាក់ខ្លួន។ លោក ត្រាំ ធ្លាប់បាននិយាយប្រាប់អ្នកកាសែតថា នឹងបញ្ចប់សង្គ្រាមនោះ ដោយបន្តជំនួយដល់អ៊ីស្រ្តាអែល នឹងបន្តរចរចាសន្តិភាព ។ លោក ណេតាញ៉ាហ៊ូ ប្រមុខរដ្ឋភិបាលអ៊ីស្រ្តាអែល មិនបានស្តាប់ឱវាទរបស់លោក បាយដិន ថា«មិនឲ្យវាយទៅលើជនស៊ីវិល»ទេ នៅពេលព្យាយាមតាមដានវាយកំទេចភេរវករ ដែលបណ្តាលឲ្យប្រជាពលរដ្ឋស៊ីវិលប៉ាឡេស្ទីនរងគ្រោះយ៉ាងអណោចអធម្ម, នោះជាហេតុធ្វើឲ្យមានការចេញដីការចាប់ខ្លួន ពីអង្គការតុលាការអន្តរជាតិកាលពីសប្តាហ៍មុន តែទណ្ឌកម្មនេះពុំបានរំខានដល់ការបន្តវាយលើក្រុមហាម៉ាស់ទេ។ លទ្ធផលគឺ មេក្រុមដឹកនាំហាម៉ាស់ បានត្រូវសម្លាប់ដោយយោធាអ៊ីស្រ្តាអែលបានជាបន្តបន្ទាប់ ឥឡូវក៏បានចូលមកអង្គុយនៅតុចរចាខ្លះៗហើយដែរ។

លោក ជោ បាយដិន នៅចុងអាណត្តិរបស់លោក មិនបានបញ្ឈប់ជំនួយទៅអ៊ីស្រ្តាអែលទេ តែបន្តរលើកទឹកចិត្តមានកិច្ចចរចាសន្តិភាព ដោយប្រទេសកាតាដដែល។ នៅអាណត្តិបន្ត

ន លោកប្រធានាធិបតីរុស្ស៊ី ពូទីន នឹងប្រធានាធិបតីអ៊ុយក្រែន ជេឡិនស្គី ទាំងពីរនាក់សុទ្ធតែសង្ឃឹមថា«សង្គ្រាមនឹងបញ្ចប់នៅឆ្នាំ២០២៥ខាងមុខ នៅពេលដែល

រីកនឹងអង់គ្លេសវិញ ទាំងកម្លាំងទ័ពនឹងសេដ្ឋកិច្ចខ្លួនកំពុងដាំក្បាលចុះ។ការដែលរុស្ស៊ី នាំកូរ៉េខាងជើងឲ្យចូលមកជួយវាយ ក្នុងសង្គ្រាមអ៊ុយក្រែន បានធ្វើឲ្យលំនឹង



លោក ប៊ិនចាមិន មេត្តាញ៉ាហ៊ូ កំពុងគ្រប់គ្រងសង្គ្រាមនៅមជ្ឈឹមបូព៌ា(សេរី លីបង់ អៀរ៉ង់)

នៃនយោបាយសហរដ្ឋដោយលោក ត្រាំ គេដឹងថាកិច្ចចរចានៅតែបន្តតែលោក ត្រាំមានបំណងដកខ្លួនចេញពីជម្លោះយោធា ឲ្យបានឆាប់រហ័ស ដែលធ្វើឲ្យអាមេរិកចំណាយលុយច្រើននោះ

លោកប្រធានាធិបតីអាមេរិក ឌណាល ត្រាំ ឡើងកាន់អំណាចជាលើកទី២ ។ អាមេរិកនៅ២ខែមុនបញ្ចប់ដំណែងលោក បាយដិន បានបង្កើនកម្លាំងឲ្យអ៊ុយក្រែន ដោយអនុញ្ញាត្តិឲ្យអ៊ុយក្រែន អាចប្រើគ្រាប់

អំណាចពិភពលោកខាងប្លុកកុម្មុយនីស្តខូចខាត ដោយកូរ៉េខាងត្បូងនឹងជប៉ុន ជាមហាអំណាចសេដ្ឋកិច្ច សម្ព័នមិត្រអាមេរិកាំង ក៏បានប្រកាសចូលទៅជួយអ៊ុយក្រែនដូចគ្នាដែរ រីឯចិនកុម្មុយនិស្តវិញ បែរជាបង្ហាញឥរិយាបទអព្យាក្រឹតចំពោះសង្គ្រាមអ៊ុយក្រែនទៅវិញ គឺមិនបានជួយរុស្ស៊ីទេ។ នៅសល់សហភាពអឺរ៉ុប ដែលជាភាគីសំខាន់ក្នុងការទប់សង្គ្រាមកុំឲ្យរាលដាលមកអឺរ៉ុប ក៏កំពុងរៀបចំខ្លួនបង្កើនសមត្ថភាពយោធាជួយទៅអ៊ុយក្រែនដែរ នៅមុនពេលដែល ឌណាល ត្រាំ ចូលមកកាន់អំណាចនៅសហរដ្ឋអាមេរិក។

***អង្គការ«អូតង់»ឬ«ណេតូ»

គឺជាសម្ព័ន្ធភាពយោធាសម្រាប់ការពារប្រទេសទាំង៣០របស់សហភាពអឺរ៉ុប មានទាំងអាមេរិកនៅក្នុងនោះដែរ។ កាលពីអាណត្តិមុនរបស់លោក ត្រាំ (ឆ្នាំ២០១៦ដល់២០២០) លោកបានបន្ថយសកម្មភាពសហរដ្ឋ ចេញពី

តទៅទំព័រទី០៨


(អ៊ុយក្រែន)៖ ប្រធានាធិបតេយ្យហ្សេលែនស្គីនៅក្នុងសមរភូមិ ផ្តល់មធ្យោបាយឲ្យបញ្ចប់សង្គ្រាម រ៉ូស្ស៊ី អ៊ុយក្រែន

ឲ្យខាងតែបាន។

***សង្គ្រាមរុស្ស៊ីនឹងអ៊ុយក្រែនៈ

នៅ១ពាន់ថ្ងៃនៃសង្គ្រាមនៅអ៊ុយក្រែ

មីស៊ីលអាមេរិក បាញ់ចូលទៅដែនដីរុស្ស៊ីបានរីឯរុស្ស៊ីវិញខិតខំបង្កើនចំនួន«អាវុធនុ្យក្លេអ៊ែ»សម្រាប់បាញ់ចូលទៅអាមេ

តមកពីទំព័រទី ០៧

## មុខមាត់សង្គ្រាមពិភពលោកពេល...

សម្ព័ន្ធភាពលោកសេរី«អូតង់»នោះ យ៉ាងគួរឲ្យព្រួយបារម្ភ ដែលមកពីការគម្រាមកំហែងរបស់សម្ព័ន្ធកុម្មុយនិស្ត។ សហរដ្ឋ



ផែនទីនៃប្រទេសសហភាពអឺរ៉ុប

អាមេរិកបានទាមទារឲ្យសមាជិក«អូតង់»ទាំងអស់ចេញវិភាគទានស្មើគ្នា(២%នៃPIB) តែប្រទេសអតីតកុម្មុយនីស្តខ្លះធ្វើមិនទាន់បាន។ ៤ឆ្នាំកន្លងមក ក្នុងអាណត្តិរបស់លោកប្រធានាធិបតី បាយដិន សហភាពអឺរ៉ុបក៏បានពង្រឹងកម្លាំងរបស់ខ្លួន មិនចង់ឲ្យរឿងហេតុរបៀបនេះ(ការគម្រាមរបស់អាមេរីក)កើតឡើងបាននៅអឺរ៉ុបម្តងទៀតឡើយ។ ចំណែកលោក បាយដិន រហូតដល់ចប់អាណត្តិ ក៏កំពុងតែជួយលើកគុណភាពអឺរ៉ុប ឲ្យអាចទប់ទល់នឹងកុម្មុយនីស្តឲ្យបាន ដោយខ្លួនឯងដែរ។ គេអាចទាយទុកជាមុនបានថា«អឺរ៉ុបនឹងមានទំនាស់នយោបាយការពារផលប្រយោជន៍ពិភពលោក ជាមួយនឹងលោកប្រធានាធិបតី ត្រាំ»ដូចគ្នានឹងកាលពីជំនាន់លោក ត្រាំ កាន់អំណាចអាណត្តិទី១នោះដែរ។

***តំបន់ឯទៀតក្នុងពិភពលោកមហាអំណាចថ្មី«ប្រីក»មាន១០ប្រទេស ប្រទេសឯទៀតជាច្រើន ដែលជាសម្ព័ន្ធមិត្តរបស់អាមេរីកាំង បានរងគ្រោះដោយអាមេរីករបស់ ឧណល ត្រាំ អាណត្តិទី១ បានប្តូរនយោបាយក្រៅប្រទេសលុបចោលនូវសម្ព័ន្ធភាពនៅអាស៊ី ដែលការពារចិនតាយវ៉ាន់ កូរ៉េខាងត្បូង នឹងជប៉ុន ពីការគម្រាមកំហែង នឹងរំលោភពីចិនកុម្មុយនិស្ត ហើយក្នុងរយពេលតែ៤ឆ្នាំបានរាលដាលទៅដល់អូស្ត្រាលីនឹងឥណ្ឌាទៀតផង ដែលសមុទ្រចិនខាងត្បូង ដែលជាសមុទ្រអន្តរជាតិ ក៏បានត្រូវពួកកុម្មុយនិស្តរំលោភកាន់កាប់នាពេលនោះ។




ផែនទីនៃប្រទេសចូលរួមក្នុងសហព័ន្ធព្រិច ដែលមហាអំណាចថ្មី




ទាំងនោះជាមេរៀនដ៏អាក្រក់ ដល់ប្រជាជននៃប្រទេសជុំវិញសមុទ្រប៉ាស៊ីហ្វិក នឹងសមុទ្រឥណ្ឌាថា«អាមេរីកនៃ ឧណល ត្រាំ បានបាត់បង់នូវឥទ្ធិពលខ្លួនក្នុងពិភពលោកទៅហើយ»ក្រដាសប្រាក់ដុល្លាពិភពលោក ក៏អាចត្រូវប្តូរបានដោយក្រុមសម្ព័ន្ធមហាអំណាចថ្មី«ប្រីក BRIC» ដែលជាហេតុធ្វើឲ្យប្រទេសទាំងឡាយដែលរងគ្រោះនោះ ខំប្រឹងក៏សាងកម្លាំងខ្លួនឯង ដោយមិនចាំបាច់ពឹងកម្លាំងអាមេរីក តាំងពីពេលនោះមក។

ដូច្នេះគេនឹងគិតថា«សហរដ្ឋអាមេរីកនៃឆ្នាំ២០២៥អាចនឹងក្លាយទៅជាខ្សោយពឹងពាក់ជាម្ចាស់ពិភពលោកមិនបានដូចមុនទៀតទេ»។ ក្នុង២ខែទៅមុខ នៅពេលលោក បាយដិន ចាកចេញពីសេដ្ឋវិមាន លោក ឧណល ត្រាំនឹងមិនប្រកាន់នយោបាយការបរទេសខុសពីមុនស្រឡះ ដែល«សម្ព័ន្ធមិត្តអាមេរីកាំងត្រូវនៅពីក្រោយអាមេរីកលេខ១ទៅវិញហើយ» ហើយក៏មិនច្បាស់ជាលោក ត្រាំ អាចគោរពកិច្ចសន្យា នាឱកាសបោះឆ្នោតបានឬក៏មិនបានផងលោកធ្លាប់ថ្លែងថា«លោកនឹងកាន់អំណាចផ្តាច់ការ នៅថ្ងៃទី១» តែលោកបន្តរថា«នឹងប្រើយោធានៅពេលប្រកាសភាពអាសន្នដើម្បីបណ្តេញជនអន្តោប្រវេសន៍ ក្នុងទ្រង់ទ្រាយធំមិនដែលមានពីមុនមក»។ ដូច្នេះសូមរង់ចាំព្រឹត្តិការភ្ញាក់ផ្អើល ពីការធ្លាក់ចុះនៃសហរដ្ឋអាមេរីកជាមួយនឹងនយោបាយស្តាំផុតនិយមរបស់អាមេរីក«ត្រាំនិយម»៕

តមកពីទំព័រទី ០៤

## ចលនា KMD ប្តេជ្ញាតស៊ូជាមួយ

ត្រូវបានប្រើជំនួសឱ្យការរក្សាយុត្តិធម៌ទៅជាអាវុធដើម្បីបម្រើផលប្រយោជន៍សម្រាប់គ្រួសារផ្តាច់ការមួយនេះដែរ។

KMD ថាដោយសារតុលាការត្រូវបានប្រើជាអាវុធសម្រាប់ចាប់អ្នករិះគន់ដាក់គុកបែបនេះហើយ ទើបសិទ្ធិជាមូលដ្ឋានក្នុងការកាត់ក្តីដោយយុត្តិធម៌ដែលមានចែងក្នុងច្បាប់ជាធរមាន បានប្រែក្លាយទៅជាការបំភិតបំភ័យចំពោះអ្នកដែលប្រឆាំងនឹងរដ្ឋាភិបាលទៅវិញសព្វថ្ងៃនេះ។ចលនាខ្មែរដើម្បីប្រជាធិបតេយ្យអំពាវនាវឱ្យសហគមន៍អន្តរជាតិ ចាត់វិធានការដាក់លាក់ចំពោះរបបដឹកនាំគ្រួសារហ៊ុន ដែលមិនអើពើនឹងការអំពាវនាវរបស់សហគមន៍អន្តរជាតិ ដោយការដាក់ទណ្ឌកម្មលើបុគ្គល និងអង្គភាពទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្ស រួមទាំងអ្នកពាក់ព័ន្ធក្នុងការគាបសង្កត់ឆ្លងដែនផងដែរ ដើម្បីឱ្យរបបដឹកនាំគ្រួសារមួយនេះដោះលែងអ្នកទោសមនសិការទាំងអស់ឱ្យមានសេរីភាពឡើងវិញ។ សម្រាប់ទិវាសិទ្ធិមនុស្សអន្តរជាតិខួបលើកទី៧៦ ឆ្នាំ២០២៤ នេះ អង្គការសង្គមស៊ីវិលនៅកម្ពុជា បាននាំគ្នាចេញសេចក្តីថ្លែងការណ៍ រួមទាំងមានការប្រារព្ធពិធីអបអរសាទរព្រោងព្រាត ដោយលើកឡើងពីការរឹតត្បិតសិទ្ធិសេរីភាពមូលដ្ឋានរបស់ពលរដ្ឋពីសំណាក់រដ្ឋាភិបាលកម្ពុជានាពេលកន្លងមកនេះ។

អង្គការលីកាដូចេញផ្សាយរបាយការណ៍របស់ខ្លួននៅថ្ងៃទី១១ ធ្នូ នេះថា ឆ្នាំ២០២៤ នេះ មានការឃាត់ ចាប់ខ្លួន និងឃុំខ្លួនក្នុងពន្ធនាគារយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅលើសកម្មជននយោបាយ សកម្មជនសហជីព សិស្សនិស្សិត សកម្មជនការពារបរិស្ថាន និងពលរដ្ឋសាមញ្ញដទៃទៀត។

របាយការណ៍ដដែលបង្ហាញថា ចំនួនអ្នកជាប់ឃុំសម្រាប់ឆ្នាំ២០២៤ នេះ គឺចំនួនជាង ១០០នាក់ (១០២នាក់) ខណៈមនុស្ស៤៥នាក់ត្រូវបានដោះលែង និងមនុស្ស ៥៧នាក់ផ្សេងទៀតបន្តនៅក្នុងពន្ធនាគារដើម្បីអនុវត្តទោស ឬកំពុងឃុំខ្លួនបណ្តោះអាសន្នសព្វថ្ងៃនេះ។

ជុំវិញខួបលើកទី៧៦ នៃទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ធ្នូ នេះ គេសង្កេតឃើញថាអតីតនាយករដ្ឋមន្ត្រីកម្ពុជា លោក ហ៊ុន សែន និងនាយករដ្ឋមន្ត្រីក្នុងអំណាច លោក ហ៊ុន ម៉ាណែត មិនបានលើកឡើងពីការលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជាទេ គ្រាន់តែសរសេរដោយខ្លីថា អបអរសាទរខួបលើកទី៧៦ ទិវាសិទ្ធិមនុស្សអន្តរជាតិប៉ុណ្ណោះ៕

# អ៊ីស្រាអែលនឹងលីបង់ ទទួលយកសំណើរឈប់បាញ់គ្នាពីសហរដ្ឋអាមេរិក

ដោយ: ខ្មែរប៉ុស្តិ៍ស.រ.អា
អឺរ៉ុប ថ្ងៃទី២៧វិច្ឆិកា២០២៤


ពលរដ្ឋលីបង់ (លីបាណុន) រីករាយនឹងទទួលការឈប់បាញ់គ្នានៅក្បែរព្រំប្រទល់ជាមួយអ៊ីស្រ្តាអែល

មកត្រឹមសប្តាហ៍មុននេះសោះ សហរដ្ឋអាមេរិកមានការខកចិត្តជាខ្លាំង




ចំពោះឥរិយាបទអ៊ីស្រាអែលដែល«មិនព្រមបញ្ឈប់ការវាយសម្រុកទៅត្បូងខាងត្បូង នឹងនៅលីបង់ តាមបំណងលោក ដោបាយដិន» ដែលបានបណ្តាលឲ្យជនភៀសខ្លួននៅលីបង់រងគ្រោះកាន់តែច្រើនណាស់ទៅហើយ,ប្រមុខអ៊ីស្រាអែលលោកណេតាញ៉ាហ៊ូ មិនទុកចិត្តពួកហេសបូឡាទេ តែក៏ចង់បំពេញចិត្តសម្ព័ន្ធមិត្រ ហើយក្រុមហេបូឡា ដែលជាសត្រូវស្ងួព្វជនោះ ក៏ចុះខ្សោយខ្លាំងណាស់ទៅហើយ។ ចំណែកនៅត្គាស្ហា នៃប៉ាឡេស្ទីនវិញ ពុំទាន់មានកិច្ចព្រមព្រាងដូចគ្នានេះនៅឡើយទេ។

ប៉ុន្តែ កាលពីថ្ងៃអង្គារទី២៥វិច្ឆិកានេះ លោក ណេតាញ៉ាហ៊ូ បានចេញសេចក្តីថ្លែងការថា«យល់ព្រមលើសេចក្តីព្រាងឈប់បាញ់គ្នា រវាង អ៊ីស្រាអែល នឹង លីបង់ រៀបរាងដោយរដ្ឋបាលលោកបាយដិននឹងប្រទេសបារាំង»។ សេចក្តីព្រាងដដែលនោះ តម្រូវឲ្យកងទ័ពនាំប្រទេសទាំង២ ដកកម្លាំងខ្លួនចេញពីបន្ទាត់ព្រំដែនលិបង់ខាងត្បូងលីបង់ ចំនួន២០ម៉ាយ ទៅក្នុងប្រទេសរបស់ខ្លួន ហើយមិនឲ្យត្រឡប់មកវិញនៅមុនរយៈពេល៦០ថ្ងៃ ដើម្បីធានាការឈប់បាញ់គ្នា។ ពត៌មាននេះបានទទួលការអបអរសាទរ ពីបណ្តាក្រុមជនភៀសខ្លួននៅលីបង់ខាងត្បូង នឹងប្រជាពលរដ្ឋអ៊ីស្រាអែល ជាង១លាននាក់ ដែលរស់នៅជាប់នឹងព្រំប្រទល់ដែនលីបង់ ក៏កំពុងតែប្តើមត្រឡប់មកទីលំនៅខ្លួនវិញ បន្ទាប់ពីបានចាកចេញ តាំងពីជាងមួយឆ្នាំមកហើយ។

ពួកហេសបូឡា ជាក្រុមភេរវកម្ម ជាសកម្មប្រយុទ្ធរបស់កងទ័ពលីបង់,អ្នកទាំងនោះនៅក្រោមការគ្រប់គ្រងរបស់ប្រទេសអ៊ីរ៉ង់ នឹងប្រទេសស៊ីរី ដែលជួយជាកងកម្លាំងប្រយុទ្ធជាប្រយោលសម្ភារៈសឹក ថវិការ នឹងមនោគមន៍អ៊ីស្លាម។ មេដឹកនាំជាច្រើនរបស់ ហេសបូឡា នឹង ហាម៉ាស់ បានត្រូវសម្លាប់នឹងកំទេចសម្ភារៈសង្គ្រាម ដោយយោធាអ៊ីស្រាអែល។ គេអាចយល់បានថា បើគ្មានការយល់ព្រមពីអាយាតូឡា នៃប្រទេសអ៊ីរ៉ង់ទេនោះ នឹងពុំមានកិច្ចព្រមព្រាងឈប់បាញ់គ្នាដូចនេះ បានឡើយ។ គេសង្ឃឹមថា កិច្ចព្រមព្រាងឈប់បាញ់គ្នានៅត្គាស្ហា នៃប្រទេសប៉ាឡេស្ទីន ដែលជាកិច្ចព្រមព្រាងចំបងជាងគេក៏អាចនឹងលើតឡើងនៅឆាប់ៗនេះដែរ៕



តមកពីទំព័រទី ០១

# អន្តរកាលនៃអាមេរិកដ៏ជ្រួលច្របល់...

ត្រាំ កើតឡើងក្នុងពេលលោកនៅធ្វើជាប្រធានាធិបតី»រីឯទោស«ក្លែងបន្លំឯកសារពន្ធ៣៤ករណីនៅរដ្ឋនូយ៉ក ក៏ត្រូវបាន«ពន្យាពេលដាក់ទោស ទៅគ្មានពេលកំណត់» ដោយសារ ត្រាំ តវ៉ាពេលបានជាប់ជាប្រធានាធិបតីអាមេរិក។ លោកត្រាំបានខិតខំពន្យាពេលកាត់ទោសព្រហ្មទណ្ឌ បានច្រើនដង នៅជ័រជ្យា នឹងនៅនូយ៉កឲ្យទាល់តែបានដល់បោះឆ្នោតរួច ឥឡូវជាប់ឆ្នោតរួចហើយក៏សន្យាថា«នឹងបណ្តេញរដ្ឋអាជ្ញា ស្មីត ដែលចេះតែតាមស៊ើបអង្កេតរឿងរ៉ាវលោកឲ្យខាងតែបាន»។

លទ្ធផលបោះឆ្នោតឈ្នះរបស់ឧណាល ត្រាំ បានតិចបំផុត ១ យកបានស្ថាប័នប្រធានាធិបតី ២ ឈ្នះបានស្ថាប័នព្រឹទ្ធសភា(៥៣ទល់៤៧ ពាក់កណ្តាលគឺ50) ៣ ឈ្នះបានស្ថាប័នសភាដំណាងរាស្ត្រ(២១៥ទល់២២០ បាក់កណ្តាលគឺ218) ជោគជ័យតិចតួចបំផុត នៅសភាទាំង២ជាន់ នឹងធ្វើឲ្យមានការយឺតយ៉ាវក្នុងការសម្រេចច្បាប់នានា ដែលត្រូវឆ្លងសភា។ មានសមាជិកសភាខ្លះមានភារៈកិច្ចក្នុងរដ្ឋបាលថ្មី ក៏ចាកចេញ ធ្វើឲ្យអាសនៈសភាខាងគណបក្សសាធារណរដ្ឋនៅទំនេ(៣អាសនៈ)ដែលត្រូវបោះឆ្នោតឡើងវិញនៅខែមេសាខាងមុខ, ហើយនៅមានសមាជិកសភាខ្លះមកពីគណបក្សឯករាជ្យ ដែលគំនិតងាករេ អាចមិនស្របតាមគណបក្សធំ ដូច្នេះគណបក្សលោកត្រាំ អាចនឹងមានចំនួនតិចជាងឬស្មើគ្នា នឹងគណបក្សប្រជាធិបតេយ្យនោះវីវរហើយ! បើលោកត្រាំចង់បញ្ចេញច្បាប់តឹងតែងណាមួយនោះ។


មហាសេដ្ឋីពីររូបនៅក្នុងបញ្ជីប្រតិបត្តិ
Vevek Ramaswamy & Elon Musk

លោក ត្រាំ កំពុងជ្រើសរើសបុគ្គលិកជំនួយការប្រធានាធិបតី ប្រមាន៣០០០នាក់ ឲ្យចូលទៅធ្វើការ ក្នុងនោះមាន១២០០នាក់ ត្រូវឆ្លងកាត់ការសម្រេចរបស់សភា។ នៅពេលនេះគេឃើញមុខមាត់ថ្មីជាច្រើន ដែលសុទ្ធតែ«មនោគមន៍ស្តាំផុតនិយម» ថ្លែងការយ៉ាំងកាចសាហាវ ដូចជា«បើបញ្ជូនជនអន្តោប្រវេសន៍ខុសច្បាប់ចេញក្នុងចំនួនដែលមិនធ្លាប់មាន បើមានបងប្អូនជាអាមេរិកាំងចង់ឃាត់ នឹងបញ្ជូនទៅជាមួយ» មន្ត្រីខ្លះទៀតថ្លែងថា«ប៉ាតែល ថា: ខ្ញុំនឹងបិទការិយាល័យអេហ្វប៊ីអាយ (FBI) តាំងពីថ្ងៃទី១ បញ្ជូនបុគ្គលិកទាំងអស់ឲ្យទៅទល់ដែន ឲ្យទៅចាប់ជនអន្ធពាល» ខ្លះទៀតថ្លែងថា«អេឡុនម៉ុកថា: ខ្ញុំនឹងលុបស្ថាប័នរដ្ឋជាច្រើន នឹងបុគ្គលិកដែលសុទ្ធតែឥតបានការចោល»...។ ចំណែកឯពួកសមាគមកសិករតវ៉ាថា«កុំបណ្តេញជនអន្តោប្រវេសន៍ចេញច្រើនពេក រកកម្មករមកធ្វើការក្នុងកសិដ្ឋានមិនបានទេ»...គេនៅចាំបានកាលពីអាណត្តិមុនរបស់លោកត្រាំ កសិដ្ឋាន រោងចក្រ ភោជនីយដ្ឋាន ... បានរងគ្រោះដោយខ្វះពលកម្មគ្មានជំនាញនេះ ដោយពួកគេខ្លាចអាជ្ញាធរចាប់ខ្លួន។ ក្នុងចំណោមជំនួយការពិសេសរបស់ត្រាំ មានមហាសេដ្ឋីលំដាប់ពិភពលោកជាច្រើនចូលរួម គេអាចនឹងបារម្ភថា«តើនឹងមានប្រយោជន៍ផ្ទាល់ខ្លួននៅក្នុងកាងារបំរើប្រទេសដែរឬទេ?»

ធ្វើឲ្យសុខភាពអាមេរិកាំងប្រសើឡើងម្តងទៀតក្នុងបំណងលុបចោល«កម្មវិធីសុខភាពអូបាម៉ា Obamacare»ដែល ត្រាំ បានសាកល្បងដកចេញ កាលពី

តទៅទំព័រទី១១




តមកពីទំព័រទី ១០

# អន្តរកាលនៃអាមេរិកដ៏ជ្រួលច្របល់...

អាណត្តិមុនម្តងរួចហើយ តែធ្វើមិនទាន់បាន។ នៅសប្តាហ៍នេះលោក ត្រាំ បានតែងតាំង ដុកទ័រ អូ នឹង កេណ្ណឺឌី ជីអរ ឲ្យមកធ្វើការរួមគ្នា ក្នុងគំនិតថា «ឲ្យមកកាត់ចំណាយដ៏ឥតប្រយោជន៍ នឹងកំចាត់ការលួចបន្លំ នៅក្នុងរដ្ឋបាលដ៏ធំមួយនេះដែលតែងតែចំណាយថវិការសុខភាពរបស់ជាតិ ក្នុងចំណាត់ថ្នាក់ទី៣ នៃថវិការជាតិទាំងមូល»។

ទំនាក់ទំនងសេដ្ឋកិច្ចជាមួយបរទេស ពន្ធនាំចូលទំនិញពីបរទេសនឹងត្រូវតម្លើងថ្លៃជាមួយ ១ ប្រទេសម៉ិកស៊ីកតម្លើង២៥%២ ប្រទេសកាណាដាតម្លើង២៥% ពីប្រទេសចិនតម្លើងបន្ថែម១០%(ទៅជា៦០%)ប្រជុំប្រទេស«ប្រីក BRICK» អាចនឹងត្រូវតម្លើង១០០% នេះក៏ជាហេតុដែលនាំឲ្យទំនិញនាំចូលក្នុងស្រុក ក៏ឡើងថ្លៃដែរ ឬក៏មានការសងសឹកតបវិញ។

សង្គ្រាមរវាងរុស្ស៊ីអ៊ុយក្រែន លោក ត្រាំ ថា: «សង្គ្រាមនៅអ៊ុយក្រែននឹងបញ្ចប់តែត្រឹម២៤ម៉ោងប៉ុណ្ណោះ» ។ មកទល់ពេលនេះ មូស្គូបានកាន់កាប់ដីនៅអ៊ុយក្រែនខាងលិច ចំនួន២០%ហើយ គឺ: ១ តំបន់ដូណេស ២ តំបន់លូហង្ស ៣ តំបន់




President Donald Trump & President Vladimir Putin

គែសុន ហើយនឹងតំបន់ហ្សាប៉ូរីហ្សា បើទោះជា យោធាមិនទាន់កាន់កាប់ពេញលេញនៅឡើយក៏ដោយ ។ ដោយសារ ក្រុងមូស្គូ នឹង ក្រុងកៀវ មានវិបត្តិមិនអាចបន្តរសង្គ្រាមបានដូចគ្នាទាំងលោក ពូទីន នឹង ជេឡិនស្គី ទំនងជាបានយល់ស្របគ្នា ថា:«សុខចិត្តឲ្យរុស្ស៊ីទទួលបានដីទាំង៤តំបន់នោះ តែ ពូទីន ទាមទាឲ្យអ៊ុយក្រែន នឹងអឺរ៉ុបទទួលស្គាល់ព្រំដែនថ្មីនោះ ជាមុនសិន នេះមិនរាប់តំបន់គ្រីមៀ បន្ថែមទេ ដោយរុស្ស៊ីយកបានរួចទៅហើយ, រីឯលោក ជេឡិនស្គី ទាមទាឲ្យអ៊ុយក្រែនដែលនៅសល់ បានចូលជាសមាជិកគ្រប់គ្រងដោយ«អូតង់»ជាមួយគ្នាផងដែរ។ មានចំណុចចុះសម្រុងគ្នាខ្លះ ហើយ តែមិនទាន់ព្រមព្រាងគ្នានៅឡើយទេ ទំនងជារង់ចាំលោកប្រធានាធិបតីឧណាល ត្រាំ ឡើងកាន់អំណាចសិន។ ពីពេលនេះរហូតដល់ពាក់កណ្តាលខែមករា២០២៥ អ៊ុយក្រែន នៅទទួលការគាំទ្រពេញទំហ៊ឹង(ជាអាវុធជាង៧០០លានដុល្លា)ពីវ៉ាស៊ីនតោន, បន្ទាប់ពីនោះទៅ ទំនងជាត្រូវដល់ទីបញ្ចប់ហើយ ពីព្រោះ ត្រាំ មានចំណូលចិត្ត ទាក់ទងជាមួយលោក ពូទីន ទៅវិញច្រើនជាង។

នៅមានព្រឹត្តការដែលបំរុងនឹងផ្ទុះ ស្មានមិនដល់ជាច្រើនទៀត ពីព្រោះមានចំណុចខ្មៅ ដែល ត្រាំ បានបំប៉ោងធ្វើឲ្យសាធារណជនជឿហើយសប្បាយរីករាយតែមួយភ្លែត មុននឹងការពិតវាចេញមកអាចមិនដូចការគិតនោះទេ។ យើងសង្ស័យថាការបណ្តេញជនអន្តោប្រវេសន៍ ការបញ្ចប់សង្គ្រាមនៅអ៊ុយក្រែន ឬក៏នៅគ្គាស្សា អាចធ្វើទៅបានតែក្នុង១ថ្ងៃមែនឬទេ?ពីព្រោះនៅមានកត្តាប្រែប្រួលជាច្រើន ដែលអាចធ្វើឲ្យជំនឿយ៉ាងជាក់ច្បាស់របស់ ត្រាំ អាចធ្វើមិនបានទៅវិញដែរ៕






# សង្គមស៊ីវិលអំពាវនាវឱ្យរដ្ឋាភិបាលដោះលែងសកម្មជនសិទ្ធិមនុស្សដែលជាប់ឃុំឱ្យមានសេរីភាពឡើងវិញ

ដកស្រង់ពីCambodia Daily

មន្ត្រីជាន់ខ្ពស់ប្រធានសមាគមការពារសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍នៅកម្ពុជា ដែលហៅកាត់ថា #អាដហុក អំពាវនាវឱ្យរដ្ឋាភិបាលកម្ពុជា ដោះលែង#សកម្មជនសិទ្ធិមនុស្ស ដែលកំពុងជាប់ឃុំទាំងអយុត្តិធម៌ ឱ្យមានសេរីភាពឡើងវិញ ដើម្បីធានានូវសុខសន្តិភាព និងការផ្សះផ្សាបង្រួបបង្រួមជាតិ។

ប្រធានសមាគមការពារសិទ្ធិមនុស្សអាដហុក លោក #នី សុខា លើកឡើងក្នុងពិធី#ធម្មយាត្រា នៅថ្ងៃទី៦ ធ្នូ នេះថា លោកអំពាវនាវឱ្យរាជរដ្ឋាភិបាលដែលជាតួអង្គសំខាន់នៃហត្ថលេខីរបស់ឧបករណ៍សិទ្ធិមនុស្ស ត្រូវឈរលើស្មារតីនៃការគោរពសិទ្ធិមនុស្ស ដោយការដោះស្រាយបញ្ហាសំខាន់ៗអំពីសិទ្ធិមនុស្ស ដូចជា ដោះលែងសកម្មជនសិទ្ធិមនុស្សដែលកំពុងជាប់ឃុំដោយសារការប្រើសិទ្ធិរបស់ពួកគេកន្លងមក ជាដើម ដើម្បីធានានូវសុខសន្តិភាព និងការផ្សះផ្សាបង្រួបបង្រួមជាតិ។

ប្រភពដដែលបញ្ជាក់ថា ការមិនឱ្យតម្លៃទៅលើសិទ្ធិមនុស្ស



បាតុកម្មរបស់សកម្មជនសង្គមស៊ីនៅភ្នំពេញ

គឺជាមហន្តរាយសម្រាប់មនុស្សជាតិធ្ងន់ធ្ងរបំផុត ដូច្នេះការដង្ហែធម្មយាត្រានៅពេលនេះ គឺដើម្បីលើកទឹកចិត្តដល់ពលរដ្ឋគ្រប់រូបឱ្យឈរលើស្មារតីនៃការគោរពសិទ្ធិមនុស្ស និងដើម្បីស្វែងរកសុខសន្តិភាពសម្រាប់មនុស្សទូទៅនៅលើពិភពលោក។

អង្គការក្រៅរដ្ឋាភិបាល និងសមាគមជិត ២០ស្ថាប័ន រួមទាំងប្រជាពលរដ្ឋ និងព្រះសង្ឃប្រមាណជា ៥០អង្គ/នាក់ បានប្រារព្ធធ្វើធម្មយាត្រា និងសិទ្ធិយាត្រា នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៤ នេះ ក្រោមប្រធានបទ «ជ្រោងតម្លៃមនុស្សជាតិ និងសិទ្ធិមនុស្ស» ដើម្បីអបអរការប្រារព្ធខួបទី៧៦ នៃទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ ធ្នូ ដើម្បីផ្សព្វផ្សាយអំពីគុណតម្លៃរបស់មនុស្សជាតិ និងសិទ្ធិមនុស្ស ឬអត្តភាពជាមនុស្ស។

ក្រុមអង្គការសមាគម និង

តទៅទំព័រទី១៥

The Lowell Regional Transit Authority

Announces




A Temporary Fare Free Pilot Program Commencing

December 1, 2024

And Continues Through September 30, 2025

(Fares may resume 10/1/2025 Subject to State Funding)

The LRTA wants to Thank Governor Maura Healey and Lieutenant Governor Kim Driscoll, as well as the Massachusetts State Legislature for funding this Fare Free Transportation Pilot Program that will greatly benefit our communities.

Lowell Regional Transit Authority

LRTA.com

# លោក ហ៊ុន សែន ចង់ឃើញចលនាក្រៅស្រុកបង្ហាញក្បាលម៉ាស៊ីនដឹកនាំ ដើម្បីលោកចេញច្បាប់ដាក់ទោស

ដកស្រង់ពីCambodia Daily

ប្រធានគណបក្សកាន់អំណាច និងជាប្រធានព្រឹទ្ធសភាកម្ពុជា លោក#ហ៊ុន សែន ចំអកឱ្យក្រុមរដ្ឋាភិបាលនិរទេសបង្ហាញសមាសភាពក្បាលម៉ាស៊ីនដឹកនាំរដ្ឋាភិបាលនិរទេសរបស់ពួកគេឲ្យបានឆាប់ ដើម្បីឲ្យលោកងាយស្រួលបង្កើតច្បាប់រៀបចំដាក់ក្រុមជ្រុលនិយមក្រៅប្រទេសជាក្រុមភេរវកម្ម។

ថ្លែងនៅក្នុងសម័យប្រជុំពេញអង្គព្រឹទ្ធសភា នារសៀលថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៤ លោក ហ៊ុន សែន បានថ្លែងយ៉ាងដូច្នេះថា លោកចង់ឱ្យប្រកាសគណៈរដ្ឋមន្ត្រីឱ្យបានលឿន តែពួកគេមិនព្រមចេញឈ្មោះ អ្នកណាធ្វើនាយករដ្ឋមន្ត្រី អ្នកណាធ្វើឧបនាយករដ្ឋមន្ត្រី អ្នកណាធ្វើរដ្ឋមន្ត្រី ដើម្បីឲ្យលោកចេញច្បាប់មួយរៀបចំដាក់ក្រុមជ្រុលនិយមក្រៅប្រទេសជាក្រុមភេរវកម្ម។

លោក ហ៊ុន សែន អះអាងថា ពួករដ្ឋាភិបាលនិរទេសមិនហ៊ានប្រកាសទេ។ លោកថា បើពួកគេហ៊ានចេញ



លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត

ប្រធានាធិបតី បានសេចក្ដីថាពួកគេកំពុងប្រឆាំងនឹងរបបរាជានិយម ព្រោះបង្កើតរដ្ឋាភិបាលមួយដែលមានប្រធានាធិបតី។

កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤ លោក ហ៊ុន សែន លើកឡើងក្នុងពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣២ ឆ្នាំ២០២៤ ថា លោកកំពុងតាមដានសកម្មភាពក្រុមប្រឆាំងដែលកំពុងញុះញង់ពលរដ្ឋខ្មែរម្ដងហើយម្ដងទៀតឱ្យធ្វើបាតុកម្មប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជា ដើម្បីអាចកំណត់បានថា តើល្មមដល់ពេលបង្កើតច្បាប់ដាក់អ្នកទាំងនោះឱ្យក្លាយក្រុមភេរវករហើយឬនៅ។

លោក ហ៊ុន សែន អះអាងថា ទង្វើក្រុមប្រឆាំងនៅពេលនេះមិនមែនត្រឹមតែធ្វើឱ្យមានទំនាស់ផ្ទៃក្នុងរបស់កម្ពុជាទេ ប៉ុន្តែនឹងនាំទៅដល់ការផ្ទុះអាវុធរវាងប្រទេសទាំងពីរថែមទៀត។ លោកថា ការមើលមុខគ្នាមិនត្រង់ជាមួយប្រទេសជិតខាង មិនមែនបញ្ហាតូចតាចឡើយ។

ឆ្លើយតបនឹងការបង្កើតចលនាតស៊ូនយោបាយក្រៅប្រទេសនេះដែរ ប្រធានរាជបណ្ឌិត្យសភាកម្ពុជា បណ្ឌិត សុខ ទូច ចង់ឱ្យរាជរដ្ឋាភិបាលកម្ពុជាប្ដឹងលោក សម រង្ស៊ី ទៅកាន់ប្រទេសដែលពួកគេកំពុងយកជាមូលដ្ឋានដើម្បីប្រកាសបង្កើតរដ្ឋាភិបាលក្រៅប្រទេស និងកម្ទេចការបង្កើតចលនាក្រៅប្រទេសនេះតែម្ដង។

បណ្ឌិត សុខ ទូច លើកឡើងថា នៅលើពិភពលោកនេះគ្មានប្រទេសណាមួយដែលទទួលបានជោគជ័យតាមរយៈចលនាបដិវត្តន៍ពណ៌ដើម្បីប្រឆាំងរាជរដ្ឋាភិបាលស្របច្បាប់នោះទេ តួយ៉ាងដូចនៅមជ្ឈិមបូព៌ា ទុយណេស៊ី លីប៊ីអ៊ុយក្រែន ដែលកំពុងក្លាយទៅជាគំនរផេះផង់។

កាលពីដើមខែវិច្ឆិកា ឆ្នាំ២០២៤ លោក សម រង្ស៊ី សម្រេចបង្កើតចលនាជាតិតស៊ូមួយនៅក្រៅស្រុក ដែលលោកអះអាងថា ជាចលនាតំណាងឆន្ទៈពិតប្រាកដឱ្យប្រជារាស្ត្រខ្មែរដែលស្រឡាញ់ជាតិ សេរីភាព និងយុត្តិធម៌ពិតប្រាកដ ហើយចលនានេះនឹងឈានទៅបង្កើតរដ្ឋាភិបាលមួយស្ថិតនៅក្រៅប្រទេសជាបណ្ដោះអាសន្ន៕





# ពលរដ្ឋប្រទេសស៊ីរីរត់សង្គ្រាមស៊ីវិលរហូតដល់ចុងបញ្ចប់

អឺរ៉ុប ទី៨ធ្នូ២០២៤

ដោយ: ខ្មែរប៉ុស្តិ៍ស.រ.អា

លោកប្រធានាធិបតី បាស្ហា អាសាត ដែលទទួលដំណែងដែលឪពុកខ្លួនបានចែកឲ្យ កាលពី២៤ឆ្នាំមុន ប៉ុបានរស់នៅដោយសុខសាន្តទេលើគំនរអំណាចផ្តាច់ការរបស់ត្រកូល អាសាតទេ។ តាំងតែពី១៤ឆ្នាំមកហើយ នៅប្រទេសស៊ីរីរបស់លោក មានសង្គ្រាមស៊ីវិលជាប្រចាំ ដោយមានឧទ្ទាមអ៊ីស្លាមក្នុងស្រុក ពុំសុខចិត្តឲ្យលោក អាសាត កាន់អំណាចបន្តរពូជបានជាសម្បត្តផ្ទាល់ខ្លួនបានទេ ក៏កាន់អាវុធចូលតស៊ូប្រឆាំងនឹងរបបផ្តាចការរបស់លោក ដោយមានការគាំទ្រកាន់តែខ្លាំងឡើង ។

ដើម្បីរក្សាអំណាច លោក បាស្ហា អាសាត បានចងសម្ព័ន្ធភាព ឬទៅពឹងពាក់ជាមួយប្រទេសរុស្ស៊ី ឌើម្បីឲ្យគេជួយពង្រឹងអំណាចលោកបន្ថែមពីលើកម្លាំងនោះ លោកបានទៅពឹងពាក់ប្រទេសអ៊ីរ៉ង់ ជាមហាអំណាចអ៊ីស្លាមមួយនៅក្នុងតំបន់ ឲ្យមកជួយថែមទៀត ។ លោក អាសាត បានបង្កើនសម្ព័ន្ធមិត្តដ៏កាចសាហាវថ្មីទៀត មកពីប្រទេស



Insurgents are pursuing a shock offensive that has quickly captured not just Aleppo, but other key cities across the country's northwest and in the south, reaching the suburbs of the capital Damascus. Omar Albam/AP

លីបង់ ដែលចិញ្ចឹមក្រុមភេរវករ អេសបូឡា ឲ្យមកជួយទប់ទល់។ ការវាយតប់ជាសមរភូមិក្នុងស្រុកនេះ បណ្តាលឲ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធប្រទេស យ៉ាងខ្ទេចខ្ទាំនឹងមានជនភៀសសឹកជាង១លាននាក់គ្មានជម្រក ។

សង្គ្រាមរ៉ាំរ៉ៃនៅស៊ីរីយូរពេកទៅ បានធ្វើឲ្យអ្នកកាសែតបន្ថយការចាប់អារម្មណ៍ តែអ្នកតស៊ូក៏នៅតែមិនអស់សង្ឃឹមនៅឡើយរហូតដល់ខែតុលាឆ្នាំ២០២៤នេះ មានការប្រែប្រួលនយោបាយនៅអឺរ៉ុប ដោយសង្គ្រាមរបស់រុស្ស៊ី ទល់នឹងអ៊ុយក្រែន បានរងសម្ពាតយ៉ាងដំណំ ដែលជាហេតុធ្វើឲ្យរុស្សិដកដៃពីស៊ីរី មកទប់ទល់យ៉ាងស្វិតស្វាញជាមួយសមរភូមិអ៊ុយក្រែនវិញ ។ ស្របជាមួយគ្នានោះ សមរភូមិគ្នាស្ហាវិញ កងកម្លាំងអ៊ីស្រ្តាអែល បានវាយចូលប្រទេសអ៊ីរ៉ង់ ដែលបានកាពារយុទ្ធជនភេរវករហាម៉ាស់ បណ្តាលឲ្យសម្លាប់មេភេរវករហាម៉ាសនៅអ៊ីរ៉ង់ បានជាបន្តរបន្ទាប់ ក៏បានធ្វើអ៊ីរ៉ង់ ងាកមកកាពារប្រទេសខ្លួនឯងវិញ ទុកស៊ីរី ឲ្យរឹតតែកំព្រាថែមទៀត សោកនាកម្មនៅស៊ីរីមិនទាន់ចប់នៅឡើយទេ ពួកភេរវករមកពីប្រទេសលីបង់ ក៏ដកខ្លួនទៅជម្រកគេវិញ ដើម្បីកាពារក្រុមពួកគេនៅឡីបង់ ដែលរងការវាយប្រហារ យ៉ាងប្រសិទ្ធិភាព លើកងឯភាពរបស់ខ្លួន។ អស់សម្ព័ន្ធមិត្តជំនួយ សម្រាប់កាពារស៊ីរី ក្រុមឧទ្ទាមអ៊ីស្លាមក៏វាយលុកយកខេត្តដ៏ធំមួយ គឺលីប៉ូ នៅថ្ងៃ២៧វិច្ឆិកា បានភ្លាម ហើយក៏បន្តរដំណើរទៅកាន់រដ្ឋធានី ដាម៉ាស់។

របបក្រុង ដាម៉ាស់ កំពុងរង្គោះរង្គើយ៉ាងខ្លាំង នៅព្រឹកថ្ងៃអាទិត្យទី៨ធ្នូនេះ គេនៅមិនទាន់ដឹងនៅឡើយថា តើលោក បាស្ហា អាសាត នៅក្នុងទីក្រុងនៅឡើយ ឬក៏គេចខ្លួនបាត់ទៅហើយ?អ្នកសង្កេតការមើលឃើញថា របបផ្តាច់ការ បាស្ហា អាសាត នេះទំនងជាមិនអាចទ្រទ្រង់នៅបានយូរតទៅទៀតឡើយ។ ពេលល្ងាចបន្តិច គេក៏បានដឹងថាប្រធានាធិបតីស៊ីរីរូបនោះ បានចាកចេញពីប្រទេសទៅបាត់ហើយ ក្រុមអ្នកស្មោះត្រង់នឹង អាសាត ក៏ចាកចេញក៏ប្រទេស ទៅកាន់ប្រទេសអ៊ីរ៉ាក់ នាល្ងាចនោះ ដាម៉ាស់ ក៏ដួលរលំទៅក្នុងដៃឧទ្ទាមភ្លាមដែរ ក្រុមអ្នកប្រយុទ្ធប្រឆាំងនឹង អាសាត ដែលមានប្រមាណជាង១០ក្រុមដាច់ពីគ្នា គាំទ្រពីប្រទេសទួគី បានប្រកាសជ័យជំនះលើកម្លាំងទ័ពរដ្ឋាភិបាលនារាត្រីនោះ។ សហរដ្ឋអាមេរិកប្រកាសមិនឲ្យកងទ័ពខ្លួន នៅក្រៅពីជ័យជំនះនេះ ចំណែកឯអ៊ីស្រ្តាអែល បានចូលកានកាប់ជំរំយោធាដែលអាសាត បោះបង់ចោល ដើម្បីត្រៀមទប់កុំឲ្យរាលដាលទៅដល់ប្រទេសខ្លួន។

គេនៅពុំទាន់ដឹងច្បាស់នៅឡើយថា តើនឹងមានក្រុមណាជាអ្នកដឹកនាំដំណើរប្រទេសស៊ីរីថ្មី ដោយរបៀបណានៅឡើយទេ ដោយក្រុមប្រយុទ្ធអ៊ីស្លាមនិមួយៗមានលក្ខណៈគ្រប់គ្រងនយោបាយមិនដូចគ្នាទេ៕





ក្រុមប្រយុទ្ធប្រឆាំងនឹងរបប បាស្ហា អាសាត បានចូលមកដល់ក្រុង ហាមា

# ក្រុមអ្នកតស៊ូមតិកម្ពុជាថា ការរំលោភសិទ្ធិមនុស្ស ធ្ងន់ធ្ងរប្រព្រឹត្តក្នុងសម័យដឹកនាំដោយត្រកូល ហ៊ុន

ដកស្រង់ពីCambodia Daily

ក្រុមអ្នកតស៊ូមតិកម្ពុជាដែលមានមូលដ្ឋាននៅប្រទេសអូស្ត្រាលី លើកឡើងថា គណបក្សប្រជាជនកម្ពុជា គឺជាអ្នកនៅពីក្រោយនៃអំពើរំលោភសិទ្ធិមនុស្សគ្រប់ទម្រង់ទាំងអស់ដែលកំពុងប្រព្រឹត្តដោយរាជរដ្ឋាភិបាលគ្រប់គ្រងដោយត្រកូលហ៊ុនសព្វថ្ងៃ។

ក្រុមអ្នកតស៊ូមតិកម្ពុជា (Cambodia Advocacy Team (#CAT)) ចេញសេចក្តីថ្លែងការណ៍វិភាគមួយនៅថ្ងៃទី៩ ធ្នូ នេះថា អំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដែលកើតមានជាប្រព័ន្ធ និងប្រព្រឹត្តដោយរដ្ឋអំណាចក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា បានចាប់ផ្តើមតាំងពីអំឡុងឆ្នាំ២០១៥ មកម្ល៉េះ ព្រោះពួកគេបានចាប់ផ្តើមអនុវត្តទង្វើនេះដោយការបង្កើតឱ្យមានច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៅឆ្នាំនោះ។

យ៉ាងណាមិញ កាលពីសប្តាហ៍មុន ក្រុមប្រឹក្សា ២៣តុលា១៩៩១ ដែលមានទីស្នាក់ការនៅទ្វីបអឺរ៉ុប បានផ្សាយលិខិតសង្ខេបមួយថា ការរំលោភបំពានសិទ្ធិមនុស្សពលរដ្ឋខ្មែរគ្រប់រូបភាពយ៉ាងធ្ងន់ធ្ងរ វាកើតមានតាំងតែពីក្រោយថ្ងៃរដ្ឋប្រហារខែកក្កដា ឆ្នាំ១៩៩៧ មកម្ល៉េះ។

ប្រភពដដែលរៀបរាប់ថា ការធ្វើវិសោធនកម្មច្បាប់ចំនួន ៣លើក ចំពោះច្បាប់ស្តីពីគណបក្សនយោបាយដើម្បីរំលាយគណបក្សសង្គ្រោះជាតិ នៅចុងឆ្នាំ២០១៧ និងហាមឃាត់សិទ្ធិមន្ត្រីជាន់ខ្ពស់ទាំង ១១៨នាក់របស់បក្សនេះក៏ជាការរំលោភសិទ្ធិមនុស្ស និងបំផ្លាញលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជាយ៉ាងព្រៃផ្សៃបំផុតដែរ។

ក្រុមអ្នកតស៊ូមតិកម្ពុជា អះអាងថា ឆ្នាំ២០១៧ នេះហើយ គឺដើមហេតុដែលនាំឱ្យសិទ្ធិមនុស្សចាប់ផ្តើមដាំក្បាលចុះធ្ងន់ធ្ងរបំផុតហូតដល់សព្វថ្ងៃនេះ ព្រោះតែគណបក្សប្រឆាំងដ៏ធំត្រូវបានរំលាយ ខណៈសមាជិកបក្សនេះជាង ១០០នាក់ក៏ត្រូវបានចាប់ខ្លួន និងកាត់ទោសពីបទក្បត់ជាតិ ស្របពេលដែលសារព័ត៌មានឯករាជ្យក៏ត្រូវរងនូវការបំផ្លិចបំផ្លាញផងដែរនោះ។

ក្រៅពីនេះ រដ្ឋាភិបាលបក្សកាន់អំណាចក៏បានចាប់ខ្លួនមេដឹកនាំបក្សប្រឆាំង លោក កឹម សុខា ទាំងមានអភ័យឯកសិទ្ធិជាសមាជិករដ្ឋសភា និងដាក់បម្រាមមិនឱ្យមន្ត្រីជាន់ខ្ពស់គណបក្សសង្គ្រោះជាតិដែលនិរទេសទៅនៅក្រៅស្រុក វិលចូលទៅក្នុងប្រទេសវិញ ក្នុងពេលដែលសកម្មជននយោបាយដែលភៀសខ្លួនរស់នៅប្រទេសជិតខាង ក៏ត្រូវបានចាប់បញ្ជូនទៅដាក់គុកនៅប្រទេសកម្ពុជាវិញថែមទៀត។



សម្តេចតេជោ ហ៊ុន សែន

លើសពីនេះ របបដឹកនាំត្រកូលមួយនេះ ក៏បានធ្វើទុក្ខបុកម្នេញទៅលើសហជីពឯករាជ្យ អ្នកសារព័ត៌មានឯករាជ្យដែលនៅសេសសល់ សកម្មជនបរិស្ថាន សកម្មជនសិទ្ធិមនុស្ស និងសកម្មជននយោបាយដទៃទៀត ដែលបង្ហាញឱ្យឃើញពីការរំលោភបំពានសិទ្ធិមនុស្សកាន់តែព្រៃផ្សៃនៅកម្ពុជាក្នុងពេលបច្ចុប្បន្ននេះ។

ប្រភពដដែលលើកឡើងថា ការរំលោភបំពានសិទ្ធិមនុស្សរបស់រដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា អស់រយៈពេលជិត ២០ឆ្នាំមកនេះ ត្រូវបានបិទបាំងដោយពាក្យថា ដើម្បីការពារសន្តិភាព ប៉ុន្តែការពិត ទង្វើទាំងអស់នេះគឺដើម្បីបំពេញមហិច្ឆតាអំណាច ធនធាន និងផលប្រយោជន៍របស់ថ្នាក់ដឹកនាំ និងសមាជិកខ្លះរបស់គណបក្សប្រជាជនកម្ពុជាប៉ុណ្ណោះ។

ក្រុមអ្នកតស៊ូមតិកម្ពុជា អំពាវនាវឱ្យស្ថាប័នសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស កោះប្រជុំឡើងវិញ ដើម្បីជំរុញឱ្យមានដំណោះស្រាយនយោបាយ ដែលឈានទៅរកការសង្គ្រោះប្រទេសកម្ពុជាពីការរំលោភសិទ្ធិមនុស្សឡើងវិញដែលកំពុងលិចលង់នាពេលនេះ។

កាលពីថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៤ អង្គការអន្តរជាតិឃ្លាំមើលសិទ្ធិពលរដ្ឋដែលហៅកាត់ថា CIVICUS បានចេញរបាយការណ៍ស្តីពី អំណាចរបស់ពលរដ្ឋសម្រាប់ឆ្នាំ២០២៤ ថាសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ស្ថិតនៅក្រោមការវាយប្រហារយ៉ាងធ្ងន់ធ្ងរ ដែលធ្វើឱ្យលំហសេរីភាពពលរដ្ឋកាន់តែធ្លាក់ចុះ៕

---

តមកពីទំព័រទី ១៦

## សង្គមស៊ីវិលអំពាវនាវឲ្យរដ្ឋាភិបាល...

ប្រជាពលរដ្ឋទាំងនេះ បានដើរដង្ហែក្បួនធម្មយាត្រាក្នុងចម្ងាយផ្លូវជាង ១៥០គីឡូម៉ែត្រចេញពីរង្វង់មូលខេត្តកំពត ឆ្ពោះទៅកាន់រាជធានីភ្នំពេញ ខណៈអ្នកចូលរួមបានដើរជាក្បួនសមាធិ កាន់បដាបង្ហាញសារស្តីពីសិទ្ធិមនុស្សផងដែរ។

ជុំវិញធម្មយាត្រានេះ ប្រធានអង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (Chrac) លោក រស់ សុផ្លា លើកឡើងថា បើគ្មានការអនុវត្តដើម្បីលើកកម្ពស់សិទ្ធិមនុស្សទេ នោះមានន័យថា មនុស្សក៏មិនត្រូវបានធានា និងការពារឱ្យមានសេចក្តីសុខដែរ។

ទាក់ទិននឹងបញ្ហានេះ អង្គការអន្តរជាតិឃ្លាំមើលសិទ្ធិពលរដ្ឋដែលហៅកាត់ថា CIVICUS បានចេញរបាយការណ៍ស្តីពី អំណាចរបស់ពលរដ្ឋសម្រាប់ឆ្នាំ២០២៤ កាលពីថ្ងៃទី៣ ខែធ្នូ នេះថា សិទ្ធិមនុស្សនៅកម្ពុជាស្ថិតនៅក្រោមការវាយប្រហារយ៉ាងធ្ងន់ធ្ងរ ដែលធ្វើឱ្យលំហសេរីភាពពលរដ្ឋកាន់តែធ្លាក់ចុះ។

របាយការណ៍ដដែលនេះ បង្ហាញថា នៅឆ្នាំ២០២៤ នេះ រដ្ឋាភិបាលកម្ពុជាដែលស្ថិតក្រោមការដឹកនាំរបស់ត្រកូលហ៊ុន បានប្រើយុទ្ធនាការគាបសង្កត់លំហសេរីភាពពលរដ្ឋ អង្គការសង្គមស៊ីវិល អ្នកការពារសិទ្ធិមនុស្ស សកម្មជនសង្គម និងនយោបាយ កាន់តែខ្លាំងឡើងៗ៕

# អតីតមេបក្សប្រឆាំងនិរទេសនៅបរទេសព្យាករថារបប លោក ហ៊ុន សែន នឹងរលំដូចប្រទេសដទៃដែរ

ដកស្រង់ពីCambodia Daily

អតីតមេដឹកនាំបក្សប្រឆាំង លោក សមរង្ស៊ី លើកឡើងថា ជោគជ័យយុទ្ធសាស្ត្រផ្ការីកនៅប្រទេសស៊ីរី ដែលបានផ្តួលរំលំត្រកូលផ្តាច់ការ អាល់អាសាដ នៅពេលនេះ ក៏នឹងជិតចាប់ផ្តើមផ្តួលរំលំរបបដឹកនាំត្រកូលហ៊ុននៅប្រទេសកម្ពុជាដែរ។

អតីតប្រធាន#គណបក្សសង្គ្រោះជាតិ លោក #សមរង្ស៊ី សរសេរលើទំព័រហ្វេសប៊ុករបស់ខ្លួននៅថ្ងៃទី៩ ធ្នូ នេះថា មេដឹកនាំផ្តាច់ការនៅស៊ីរី បាល់សាល អាល់អាសាដ (#Bashar Al-Assad) នៅប្រទេសស៊ីរី បានរត់គេចខ្លួនទៅប្រទេសកុម្មុយនីស្តរុស្ស៊ី ហើយ ទោះបីជាប្រទេសស៊ីរី គ្រប់គ្រងដោយរបបផ្តាច់ការពីឪពុកទៅកូនក្នុងត្រកូលអាសាដអស់រយៈពេលជាង ៥០ឆ្នាំក៏ដោយ ក៏ចុងក្រោយនៅតែរបបនេះដួលរលំដែរ។

លោក សម រង្ស៊ី លើកឡើងថា យុទ្ធសាស្ត្រផ្ការីកដែលលោកប្រកាសបានធ្វើឲ្យលោកហ៊ុន សែនភ័យស្លន់ស្លោរហូតដល់វង្វេងហើយនៅពេលនេះ។ លោកថា បន្តិចទៀត តាមហាង ឬតូបលក់ផ្កានៅតាមផ្សារ និងចម្ការផ្កានៅតាមជនបទ ក៏នឹងត្រូវលោក ហ៊ុន សែន ចោទប្រកាន់ថាជា "សម្ព័ុកភេរវករ" ដែរ ព្រោះគាត់កំពុងភ័យស្លន់ស្លោនឹងយុទ្ធសាស្ត្រផ្ការីកនេះ។

អតីតមេដឹកនាំបក្សប្រឆាំងរូបនេះ បញ្ជាក់ថា ដោយសារតែការភ័យខ្លាចនឹងយុទ្ធសាស្ត្រផ្ការីក លោក ហ៊ុន សែន



លោក សម រង្ស៊ី និរទេសខ្លួន ព្យាករណ៍ថា ហ៊ុន សែន នឹងរលំ

ច្បាស់ជានឹងចោទប្រកាន់អ្នកដើរតាមផ្លូវដែលកាន់ផ្កាមួយទង ឬនារីណាដែលសៀតផ្កានៅត្រចៀក ថាជា "ភេរវករ" មិនខានទេ ខណៈពុទ្ធបរិស័ទដែលយកផ្កាទៅថ្វាយព្រះនៅតាមវត្តអារាម ក៏អាចនឹងត្រូវលោក ហ៊ុន សែន ចោទប្រកាន់ថាជា "ក្រុមភេរវករ" ឬក្រុមឧទ្ទាមដែរ។

ក្រោយដួលរលំរបបផ្តាច់ការ លោក បាល់សាល អាល់អាសាដ (Bashar Al-Assad) និងក្រុមគ្រួសារបានរត់ភៀសខ្លួនទៅជ្រកកោននៅប្រទេសរុស្ស៊ីចំណែកឯនាយករដ្ឋមន្ត្រីនៃរបបនេះមិនអាចរត់គេចខ្លួនបានឡើយ។

ជុំវិញបញ្ហានេះ មន្ត្រីជាន់ខ្ពស់គណបក្សសង្គ្រោះជាតិ លោក មុត ចន្ថា សរសេរលើគណនីហ្វេសប៊ុករបស់ខ្លួននៅថ្ងៃទី៩ ធ្នូ នេះថា កុំថាឡើយរបបដឹកនាំផ្តាច់ការដែលមានអាយុ ៣៥ឆ្នាំ សូម្បីមានអាយុ ៥៣ឆ្នាំ ក៏ដួលរលំដែរ ព្រោះនៅទីបំផុត ជនផ្តាច់ការត្រូវតែដល់ថ្ងៃអវសាន។

លោក មុត ចន្ថា លើកឡើងថា អ្នកតស៊ូដើម្បីសេរីភាព និងប្រជាធិបតេយ្យ មិនត្រូវអស់សង្ឃឹម ព្រោះតែការប្រយុទ្ធដើម្បីសេរីភាព និងយុត្តិធម៌នោះទេ។

ចូលដល់ឆ្នាំ២០២៤ នេះ គេសង្កេតឃើញថារបបដឹកនាំផ្តាច់ការបានដួលរលំជាបន្តបន្ទាប់។ ជាក់ស្តែង នៅអំឡុងខែសីហា របបដឹកនាំផ្តាច់ការនៅបង់ក្លាដេស ត្រូវបានដួលរលំ ខណៈនាយករដ្ឋមន្ត្រីនៃប្រទេសនេះ គឺអ្នកស្រី ហ្សេក ហាស៊ីណា (Sheikh Hasina) ត្រូវរត់គេចខ្លួនចាកចេញពីប្រទេសភ្លាមៗ។

ចំណែកមេដឹកនាំរបបសឹកនៅប្រទេសភូមា លោក មីន អ៊ុងឡាំង (Min Aung Hlaing) ក៏ត្រូវរដ្ឋអាជ្ញានៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) ដាក់សំណើទៅចៅក្រមនៃតុលាការនេះឱ្យចេញដីកាចាប់ខ្លួនផងដែរ កាលពីចុងខែវិច្ឆិកាកន្លងទៅនេះ។ ដោយឡែកប្រធានាធិបតីកូរ៉េខាងត្បូង លោក យន់ សុខយុល (Yoon Suk Yeol) ដែលប្រកាសប្រើច្បាប់អាជ្ញាសឹកកាលពីពេលថ្មីៗនេះ ក៏ត្រូវបរាជ័យយ៉ាងធ្ងន់ធ្ងរដែរ បន្ទាប់ពីប្រជាពលរដ្ឋចេញធ្វើបាតុកម្មតវ៉ា ក្រោមហេតុផលថា ការប្រកាសប្រើច្បាប់អាជ្ញាសឹកពីប្រធានាធិបតីរូបនេះជាចេតនាទាញប្រទេសកូរ៉េខាងត្បូង ឱ្យងាកទៅរករបបដឹកនាំបែបផ្តាច់ការ៕

# រដ្ឋាភិបាលកម្ពុជាចាត់ទុកចលនាតស៊ូនៅក្រៅស្រុករបស់លោក សម រង្ស៊ី ថាជាចលនាធ្វើឱ្យមនុស្សស្លាប់

ដកស្រង់ពីCambodia Daily

អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកការបង្កើតចលនាតស៊ូនៅក្រៅស្រុករបស់អតីតមេដឹកនាំបក្សប្រឆាំង លោក សមរង្ស៊ី ថាជាការញុះញង់បញ្ឆេះកំហឹង ធ្វើឲ្យមានហិង្សាវឹកវរក្នុងសង្គម និងធ្វើឱ្យមនុស្សស្លាប់។

ប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល លោក ប៉ែនបូណា លើកឡើងក្នុង



លោក ប៉ែន បូណា ប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជា

កិច្ចពិភាក្សាតុមូលស្តីពី «ការបង្កើតចលនាតស៊ូនយោបាយក្រៅស្រុក» នៅរាជបណ្ឌិត្យសភាកម្ពុជា នាថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៤ នេះថា ការបង្កើតចលនាតស៊ូនៅក្រៅប្រទេស គ្រាន់តែជាល្បិចប្រើប្រាស់ប្រជាពលរដ្ឋជាឈ្នាន់ដើម្បីឈោងចាប់អំណាចរបស់លោក សមរង្ស៊ី ប៉ុណ្ណោះ។

លោក ប៉ែន បូណា អះអាងថា ការបង្កើតចលនាតស៊ូនៅក្រៅប្រទេសក្រៅប្រព័ន្ធបោះឆ្នោតរបស់កម្ពុជាបែបនេះ គឺជាការប៉ុនប៉ងអូសទាញប្រទេសជាតិឲ្យដើរថយក្រោយយ៉ាងជាក់ច្បាស់ ព្រោះថាមិនមានអ្នកប្រជាធិបតេយ្យឯណា

តទៅទំព័រទី១៨

## Lowell Primary Care Center
## មណ្ឌលថែទាំសុខភាព Lowell

1075 Westford Street, Unit 204
Lowell, MA 01851 • (978) 455-7992

BAYON MEDICAL GROUP
BMG

## Lynn Primary Care Center
## មណ្ឌលថែទាំសុខភាព Lynn

280 Union Street, Unit 402
Lynn, MA 01901 • (781) 780-7755



**Chhan Touch, FNP-BC**
ឆាន់ ទូច



**Practice Manager**
**Channa Khan, CMA**
អ្នកគ្រប់គ្រងគ្រូពេទ្យ
ចាន់ណា ខាន់



**Sophor Chhour, LMHC**
សុភ័រ ឈួ



**Nalyne Dom, FNP-BC**
ណាលីន ដំ



**Nida Lam, FNP-BC**
នីដា ឡាម



**Maredy Sar, DNP, NP-C**
ម៉ារីឌី ស



**Miadette Pheng-Phal, DNP, NP-C**
មីយ៉ាដេត ផេងផល

## Now Accepting New Patients
## ឥឡូវនេះ បើកទទួលអ្នកជំងឺថ្មី

***Family Medicine***
*ថែទាំសមាជិកគ្រួសារ*

***Behavioral Health***
*ថែទាំសុខភាពផ្លូវចិត្ត*

**We Accept MassHealth, Medicare and Other Health Insurances**
**Our Staff Speaks Khmer**

យើងទទួល **MassHealth Medicare** និងការធានារ៉ាប់រងសុខភាពផ្សេងៗ
បុគ្គលិករបស់យើងនិយាយភាសាខ្មែរ

# ពលរដ្ឋខ្មែរអាមេរិកាំងប្រកាសធ្វើសមាជស្តីអំពីបញ្ហាកោះគុត

ដកស្រង់ពីCambodia Daily

ប្រធានចលនាខ្មែរដើម្បីសិទ្ធិប្រជាធិបតេយ្យ (Khmer Movement for Democracy (#KMD)) ប្រកាសធ្វើសមាជពលរដ្ឋខ្មែរអាមេរិកាំងនៅលើទឹកដីសហរដ្ឋអាមេរិកស្តីពីបញ្ហា#កោះគុត នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៤ ដើម្បីកៀរគរប្រជាពលរដ្ឋឱ្យជួយជំរុញរដ្ឋាភិបាលកម្ពុជាប្ដឹងថៃ ទៅ #តុលាការអន្តរជាតិ ដើម្បីទាមទាចំណែកកម្មសិទ្ធិលើកោះគុតត្រឡប់មកវិញ។

ប្រធានចលនាខ្មែរដើម្បីសិទ្ធិប្រជាធិបតេយ្យ អ្នកស្រី #មូរសុខហួរ ចេញសេចក្ដីជូនដំណឹងកាលពីថ្ងៃទី៥ ខែធ្នូ ថា ចលនាខ្មែរដើម្បីប្រជាធិបតេយ្យ នឹងប្រារព្ធធ្វើសមាជពលរដ្ឋខ្មែរអាមេរិកាំងរដ្ឋកាលីហ្វ័រញ៉ា នៅទីក្រុងឡុងប៊ិច ស្តីពីបញ្ហាកោះគុត នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៤។

ប្រធានចលនាខ្មែរដើម្បីសិទ្ធិប្រជាធិបតេយ្យរូបនេះបញ្ជាក់ថា សមាជនេះនឹងចាប់ផ្ដើមពិធីពីម៉ោង ២រសៀលរហូតដល់ម៉ោង ៦ល្ងាច ស្ថិតក្នុងអាសយដ្ឋាន 1240 E. Carson Street, Long Beach Ca 90807។

ការប្រកាសធ្វើសមាជពលរដ្ឋខ្មែរអាមេរិកាំងនេះ ធ្វើឡើងដើម្បីកៀរគរប្រជាពលរដ្ឋឱ្យជួយជំរុញរដ្ឋាភិបាលកម្ពុជាប្ដឹងថៃ ទៅតុលាការអន្តរជាតិ ដើម្បីទាមទារចំណែកកម្មសិទ្ធិលើកោះគុតត្រឡប់មកវិញ។

ជុំវិញបញ្ហានេះ ពលករខ្មែរក្នុងប្រទេសកូរ៉េខាងត្បូង ក៏បានប្រកាសកាលពីថ្ងៃទី៥ ខែធ្នូ នេះដែរថា ពួកគេនឹងប្រារព្ធពិធីមួយនៅទីក្រុងខាងជូងធំ នៃសាធារណរដ្ឋកូរ៉េ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៤ នេះដែរ ដើម្បីអបអរសាទរទិវាសិទ្ធិមនុស្ស ១០ធ្នូ ផង ហើយក៏នឹងធ្វើបាតុកម្មទាមទារឱ្យរដ្ឋាភិបាលកម្ពុជាប្ដឹងថៃ ទៅតុលាការអន្តរជាតិទាមទាចំណែកកម្មសិទ្ធិគ្រប់គ្រងលើកោះគុតផងដែរ។



លោកស្រី មូ សុខហួ អតីតរដ្ឋមន្ត្រីកិច្ចការនារីដឹកនាំបាតុកម្មនៅក្រៅប្រទេស

ទាក់ទិននឹងបញ្ហានេះ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ លោក អ៊ុំ សំអាន សរសេរលើទំព័រហ្វេសប៊ុករបស់ខ្លួននៅថ្ងៃទី៦ ធ្នូ នេះថា ត្រកូលហ៊ុនគិតលុយសម្រាប់ក្រុមគ្រួសារខ្លួនឯងជាធំ ជាជាងផលប្រយោជន៍របស់ប្រទេសជាតិ។

លោកថា លោក ហ៊ុន សែន សុខចិត្តប្រគល់កោះគុតដែលជាទឹកដីរបស់ខ្មែរឱ្យទៅថៃ ដើម្បីឱ្យរដ្ឋាភិបាលថៃ ជួយបួមប្រេងក្នុងតំបន់ត្រួតស៊ីគ្នាយកលុយចែកគ្នា ដើម្បីពង្រឹងអំណាចផ្ដាច់ការរបស់គាត់។

លោក អ៊ុំ សំអាន លើកឡើងថា រដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយលោក ហ៊ុន សែន បានប្រគល់កោះគុតទៅឱ្យប្រទេសថៃតាំងពីចុះកិច្ចព្រមព្រៀងលើអនុស្សរណៈនៃការយោគយល់ឆ្នាំ២០០១ (MOU44) មកម្លេះ ក្នុងនោះរដ្ឋមន្ត្រីការបរទេស លោក ស៊ូរៈកៀតសៈធានថៃ (Surakiart Sathirathai) អះអាងថា លោក ហ៊ុន សែន មិនទាមទារយកកោះគុតវិញទេ ប៉ុន្តែរដ្ឋាភិបាលថៃមិនបានប្រកាសជាសាធារណៈទេ ព្រោះខ្លាចមានការតវ៉ាទាមទារពីពលរដ្ឋខ្មែរ។

អនុស្សរណៈនៃការយោគយល់ឆ្នាំ២០០១ (MOU44) ត្រូវបានចុះហត្ថលេខាក្នុងរដ្ឋាភិបាលដែលដឹកនាំដោយលោកថាក់ស៊ីន ស៊ីណាវ៉ាត់ ដែលតំណាងដោយរដ្ឋមន្ត្រីការបរទេស លោក ស៊ូរៈកៀតសៈធានថៃ (Surakiart Sathirathai) និងឧបនាយករដ្ឋមន្ត្រីកម្ពុជា លោក សុខ អាន ដែលទទួលបន្ទុកកិច្ចការជាមពលនាពេលនោះ។

ផែនទីឧបសម្ពន្ធភ្ជាប់អនុស្សរណៈនៃការយោគយល់ឆ្នាំ២០០១ បានបង្ហាញថា លោក សុខ អាន បានកាត់កោះគុតឱ្យប្រទេសថៃ នៅឆ្នាំ២០០១ តាមបញ្ជាលោក ហ៊ុន សែន បាត់ទៅហើយ ព្រោះខ្សែបន្ទាត់លើផែនទីនោះបានគូសវាងកោះគុតចូលមកក្នុងដែនសមុទ្រខ្មែរ។

ជុំវិញបញ្ហានេះ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤ ទាំងលោក ហ៊ុន សែន និងលោក ហ៊ុន ម៉ាណែត បានលើកឡើងពីបញ្ហាកោះគុតដែរ ប៉ុន្តែពីរនាក់ឪពុកកូននេះមិនបានបញ្ជាក់ថា កម្ពុជាមានចំណែកក្នុងការគ្រប់គ្រងកោះគុត ឬក៏អត់នោះទេ ប៉ុន្តែអ្វីដែលលោក ហ៊ុន សែន បញ្ជាក់ច្បាស់នៅថ្ងៃនោះ គឺគាត់មានគម្រោងបង្កើតច្បាប់ដាក់អ្នកដែលទាមទារឱ្យប្ដឹងថៃ រឿងកោះគុតទៅតុលាការអន្តរជាតិ ជាក្រុមគេរករឿងទៅវិញ៕

តមកពីទំព័រទី ១៦

## រដ្ឋបាលកម្ពុជាចាត់ទុកចលនា...

ប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលដែលកើតចេញពីការបោះឆ្នោតដោយស្របច្បាប់នោះឡើយ។

អ្នកនាំពាក្យរាជរដ្ឋាភិបាលរូបនេះបញ្ជាក់ថា លោក សម រង្ស៊ី តែងតែបង្កបញ្ហានៅក្នុងស្រុក ដែលទង្វើនេះផ្ទុយស្រឡះពីចេតនារបស់រាជរដ្ឋាភិបាលដែលខិតខំរក្សាសន្តិភាព និងថែរក្សាសេចក្ដីសុខជូនប្រជាពលរដ្ឋរហូតមក។

អតីតមេដឹកនាំបក្សប្រឆាំង លោក សម រង្ស៊ី លើកឡើងនៅថ្ងៃទី៦ ធ្នូ នេះថា បើប្រជាពលរដ្ឋខ្មែរនាំគ្នាផ្លាស់ប្ដូររបបដឹកនាំនៅកម្ពុជាសព្វថ្ងៃនេះ គ្មានអ្វីត្រូវខាតដល់ប្រទេសជាតិទេ គឺមានតែចំណេញទៅវិញ។

លោកថា ដើម្បីផ្លាស់ប្ដូររបបដឹកនាំសព្វថ្ងៃនេះបានសម្រេចត្រូវប្រើយុទ្ធសាស្ត្រផ្ការីកដែលដឹកនាំដោយចលនាជាតិតស៊ូនៅក្រៅប្រទេស ព្រោះក្នុងយុទ្ធសាស្ត្រនេះមិនចាំបាច់លើកកម្លាំងទៅវាយយកទីតាំងណាមួយពីក្រៅទេ តែត្រូវប្រើវិធីឲ្យកម្លាំងបង្កប់នៅខាងក្នុង។

លោកសមរង្ស៊ីអះអាងថាយុទ្ធសាស្ត្រផ្ការីក គឺត្រូវរៀបចំ និងបង្កើនកម្លាំងបង្កប់


ក្រុមអ្នកកាសែតនៅកម្ពុជា

ដោយលើកទឹកចិត្តអ្នកតស៊ូដែលស្រឡាញ់ជាតិ និងស្រឡាញ់យុត្តិធម៌ ហើយស្អប់ខ្ពើមអំណាចផ្ដាច់ការ អំពើពុករលួយ ភាពអយុត្តិធម៌ របបគ្រួសារនិយម និងទង្វើក្បត់ជាតិ ជាអ្នកធ្វើសកម្មភាពបំផ្ទុះពីខាងក្នុងមកវិញ។

កាលពីដើមខែវិច្ឆិកា ឆ្នាំ២០២៤ លោក សម រង្ស៊ី សម្រេចបង្កើត#ចលនាជាតិតស៊ូមួយនៅក្រៅស្រុក ដែលលោកអះអាងថាជាចលនាតំណាងឆន្ទៈពិតប្រាកដឱ្យប្រជារាស្ត្រខ្មែរដែលស្រឡាញ់ជាតិ សេរីភាព និងយុត្តិធម៌ពិតប្រាកដ៕

# អតីតមន្ត្រីបក្សសង្គ្រោះជាតិជិត ២០នាក់ទទួលការផ្តល់តំណែងជាទីប្រឹក្សានៅជាប់នឹងលោក ហ៊ុន សែន

ដកស្រង់ពីCambodia Daily

នៅឯប្រទេសកម្ពុជាវិញ មេដឹកនាំបក្សកាន់អំណាច លោក ហ៊ុនសែន សម្រេចតែងតាំងអតីតសកម្មជនបក្សប្រឆាំងប្រចាំប្រទេសជប៉ុន លោក #ហៃ វណ្ណា ជាមួយអ្នកចុះចូលបក្សកាន់អំណាច ១៨នាក់ផ្សេងទៀតជាទីប្រឹក្សា និងជំនួយការផ្ទាល់ខ្លួន។

អតីតនាយករដ្ឋមន្ត្រីដែលកំពុងបន្តក្តោបក្តាប់អំណាច លោក ហ៊ុន សែន បានចេញសេចក្តីសម្រេចមួយកាលពីថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ ដែលទើបនឹងត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី៩ ធ្នូ នេះ ស្តីពីការតែងតាំងសកម្មជននយោបាយបក្សប្រឆាំងជិត ២០នាក់ (១៩នាក់) ជាជំនួយការ និងជាទីប្រឹក្សា។

ក្នុងចំណោមអ្នកដែលត្រូវបានតែងតាំងទាំងនេះ គឺមានអតីតសកម្មជនបក្សប្រឆាំងនៅប្រទេសជប៉ុន លោក ហៃ វណ្ណា អតីតចៅសង្កាត់គណបក្សសង្គ្រោះជាតិ លោក សារ៉ូ សុវុឌ្ឍិ និងអតីតមេធាវីគណបក្សភ្លើងទៀន លោក សំ សុគង់ ផងដែរ ដែលត្រូវបានតែងតាំងជាទីប្រឹក្សាឲ្យលោកហ៊ុនសែន។ ចំណែកឯមនុស្ស ១៦នាក់ផ្សេងទៀត ក៏ត្រូវបានតែងតាំងជាទីប្រឹក្សា និងជំនួយការរបស់លោក ហ៊ុន សែន លើលិខិតតែងតាំងក្នុងកាលបរិច្ឆេទដូចគ្នាដែរ។

អតីតសកម្មជនបក្សប្រឆាំងប្រចាំប្រទេសជប៉ុន លោក ហៃ វណ្ណា បានសុំចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា កាលពីពាក់កណ្តាលខែតុលា ឆ្នាំ២០២៤ ជាថ្នូរនឹងការដោះលែងប្អូនប្រុសបង្កើតរបស់លោក គឺលោក ហៃ វណ្ណនិត ឱ្យមានសេរីភាពឡើងវិញ បន្ទាប់ពីត្រូវបានចាប់ខ្លួន ក្រោយការប្រកាសឱ្យមានការធ្វើបាតុកម្មប្រឆាំងគម្រោងអភិវឌ្ឍន៍ត្រីកោណ (CLV-DTA) កាលពីអំឡុងខែសីហា កន្លងទៅ។

ចំណែកអតីតមេធាវីគណបក្សភ្លើងទៀន លោក សំ សុគង់ ក៏បានដាក់លិខិតជាផ្លូវការទៅកាន់លោក ហ៊ុន សែន ដើម្បីស្នើសុំចូលរួមជីវភាពនយោបាយជាមួយគណបក្សប្រជាជនកម្ពុជា កាលពីដើមខែធ្នូឆ្នាំ២០២៣កន្លងទៅដែរ។ ដោយឡែកអតីតចៅសង្កាត់ជាប់ឆ្នោតក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ របស់គណបក្សសង្គ្រោះជាតិ លោក សារ៉ូ សុវុឌ្ឍិ បាន



សម្តេច ហ៊ុន សែន ជួបជាមួយនិស្សិតខ្មែរនៅប្រទេសអារ៉ាប់រួម



សម្តេច ហ៊ុន សែន ធ្វើដំណើរទៅទស្សនៈកិច្ចនៅប្រទេសអារ៉ាប់រួម

ប្រកាសចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា តាំងពីចុងខែមេសា ឆ្នាំ២០២៣ មកម្ល៉េះ។

ក្រោយពីមន្ត្រី និងសកម្មជនបក្សប្រឆាំងចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា លោក ហ៊ុន សែន បានផ្តល់តំណែងតួនាទីដល់អ្នកទាំងនោះតាមក្រសួងស្ថាប័ននីមួយៗគ្រប់ៗគ្នា ដោយតែងតាំងជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការទីប្រឹក្សាឬជំនួយការជាដើម។

ជុំវិញបញ្ហានេះ គេសង្កេតឃើញថា ការតែងតាំងមន្ត្រី និងសកម្មជនបក្សប្រឆាំង គឺជាល្បិចនយោបាយរបស់លោក ហ៊ុន សែន ដើម្បីកម្ចាត់ក្រុមប្រឆាំងឱ្យអស់ពីប្រទេសកម្ពុជា ស្ថិតក្រោមយុទ្ធសាស្ត្រយកលលកទៅទាក់លលក ដែលមានន័យថា យកក្រុមប្រឆាំងទាក់ទាញក្រុមប្រឆាំងឱ្យចុះចូលជាមួយគណបក្សប្រជាជនកម្ពុជាប៉ុណ្ណោះ។

គួរបញ្ជាក់ថា៖ មនុស្សដែលទៅសុំទោស សុំចុះចូល ឬវិលត្រឡប់ទៅចូលរួមជីវភាពនយោបាយជាមួយបក្សប្រជាជនកម្ពុជា ឬជាមួយលោក ហ៊ុន សែន វិញ មានមួយចំនួនដើរតួប្រឆាំងដាច់អហង្ការជេរប្រមាថលោក ហ៊ុន សែន ឥតសំចៃមាត់។ មានមួយចំនួនទៀត លោក ហ៊ុន សែន ប្រកាសថាជាមនុស្សលោកបង្កប់ជាមួយពួកប្រឆាំង ហើយស្ម័គ្រចិត្តយកការណ៍រាយការណ៍ឲ្យលោកហ៊ុនសែនដើម្បីយកលាភសក្ការៈជាអ្វីមួយ។

កាលពីពាក់កណ្តាលខែមិថុនា ឆ្នាំ២០២៤ កន្លងទៅនេះ លោក ហ៊ុន សែន បានណែនាំសមាជិកបក្សកាន់អំណាចគ្រប់រាជធានី-ខេត្ត ឱ្យនាំគ្នាប្រើយុទ្ធសាស្ត្របំផ្លាញក្រុមប្រឆាំងឱ្យអស់នៅមុនសម័យបោះឆ្នោតឆ្នាំ២០២៧ និងឆ្នាំ២០២៨។

លោក ហ៊ុន សែន បានបញ្ជាឱ្យសមាជិកទាំងនោះប្រើវិធីអូសទាញសកម្មជនបក្សប្រឆាំង ឱ្យចុះចូលជាមួយបក្សកាន់អំណាចឱ្យអស់ពីមូលដ្ឋាន ដើម្បីឱ្យពួកគេទៅអូសទាញក្រុមប្រឆាំងបន្តទៀត ប៉ុន្តែបើអូសទាញមិនបានទេ ត្រូវតែបំផ្លាញចោល កុំឱ្យពួកគេនៅធ្វើជាឧបសគ្គ។

អ្នកសង្កេតការណ៍ខ្លះនិយាយបែបចំអកថា នេះជាប្រជាធិបតេយ្យបែបពួកក្រហមកុម្មុយនីស្ត៕

# សង្គមស៊ីវិលជាង ១០ស្ថាប័នស្នើឱ្យរដ្ឋាភិបាលកម្ពុជា ធានាអំពីសិទ្ធិរបស់អ្នកសារព័ត៌មានត្រូវបានការពារ

ដកស្រង់ពីCambodia Daily

ក្រុមអង្គការសង្គមស៊ីវិលជាតិ និង អន្តរជាតិចំនួន ១៤ស្ថាប័ន បានស្នើឱ្យ រដ្ឋាភិបាល#កម្ពុជា ធានាអំពីសិទ្ធិរបស់ #អ្នកសារព័ត៌មានត្រូវបានការពារ ជាពិសេសនៅក្នុងប្រទេសដែលសម្បូរ ដោយព័ត៌មានមិនពិត ដែលត្រូវបាន រដ្ឋាភិបាល និងអ្នកមានអំណាចយកទៅ ប្រើប្រាស់ បន្ទាប់ពីអ្នកកាសែតម្នាក់ត្រូវ បានឃាតករបាញ់សម្លាប់កាលពីសប្តាហ៍ មុននៅខេត្តសៀមរាប។

នៅក្នុងសេចក្តីថ្លែងការណ៍រួមចុះ ថ្ងៃទី១០ ខែធ្នូ ក្រុមសង្គមស៊ីវិលជាតិ និង អន្តរជាតិចំនួន ១៤ស្ថាប័ន បានស្នើឱ្យ រដ្ឋាភិបាលកម្ពុជា ធានាថាសិទ្ធិរបស់អ្នក សារព័ត៌មានត្រូវបានការពារ ជាពិសេស នៅក្នុងប្រទេសដែលសម្បូរដោយ #ព័ត៌មានមិនពិត ដែលត្រូវបានរដ្ឋាភិបាល និងអ្នកមានអំណាចយកទៅប្រើប្រាស់។

ប្រភពដដែលបានកត់សម្គាល់ឃើញ ថា នៅកម្ពុជា ការគាបសង្កត់ភាគច្រើន បានសំដៅទៅលើអ្នកសារព័ត៌មានដែល រាយការណ៍ពីបញ្ហារសើប ដូចជា ការ បំផ្លិចបំផ្លាញបរិស្ថាន ការជួញដូរមនុស្ស ពលកម្មដោយបង្ខំ និងឧក្រិដ្ឋកម្មក្នុង ប្រទេស។

ក្រុមសង្គមស៊ីវិលជាង ១០ស្ថាប័ន នេះ បានសម្តែងក្តីតក់ស្លុតយ៉ាងខ្លាំង ចំពោះហេតុការណ៍បាញ់សម្លាប់លោក ឈឿង ឆេង នៅពេលដែលលោកចុះ ទៅយកព័ត៌មាន។ តាមក្រុមសង្គមស៊ីវិល ថាការបង្កឧក្រិដ្ឋកម្មទៅលើអ្នកសារព័ត៌មាន ដែលបំពេញការងាររបស់ខ្លួន នឹងមិន ត្រូវបានអត់ឱនជាដាច់ខាត។



អ្នកសារព័ត៌មានបានត្រូវគំរាមដោយប៉ូលិសខ្មែរ

អ្នកសារព័ត៌មានអនឡាញមកពី អង្គភាពសារព័ត៌មានកម្ពុជាអភិវឌ្ឍន៍ ក្នុងខេត្តសៀមរាប លោក ឈឿង ឆេង ត្រូវបានបាញ់ប្រហារឲ្យរងរបួសធ្ងន់ កាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ ហើយ បានស្លាប់នៅយប់ម៉ោង ២យប់ឈាន ចូលថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៤ នៅមន្ទីរពេទ្យ បង្អែកខេត្តសៀមរាប។

អ្នកនាំពាក្យ លោក ទេព អស្នារិទ្ធ បានប្រាប់អ្នកសារព័ត៌មានថា សំណុំរឿង ឃាតកម្មលើអ្នកកាសែត ឈឿង ឆេង កំពុងស្ថិតក្រោមការយកចិត្តទុកដាក់ របស់ក្រសួងព័ត៌មាន រដ្ឋបាលខេត្ត សៀមរាប និងអាជ្ញាធរពាក់ព័ន្ធ។ ក្រសួង ព័ត៌មាន ក៏កំពុងបន្តតាមដានការវិវឌ្ឍ និងត្រៀមជួយជ្រោមជ្រែងនៅក្នុង ដំណើរការនៃការអនុវត្តនីតិវិធីច្បាប់នៅ តុលាការដែរ។

លោកថា ក្រសួងព័ត៌មានបាន យកចិត្តទុកដាក់លើការបំពេញការងារ របស់អ្នកកាសែត តាមរយៈការលើក កម្ពស់សិទ្ធិសេរីភាពវិស័យសារព័ត៌មាន តាមរយៈការផ្តល់បរិយាកាសអំណោយ ផលដល់ការប្រកបអាជីពកាសែត។

នៅក្នុងសេចក្តីថ្លែងការណ៍របស់ អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (RSF) នៅថ្ងៃទី៨ ខែធ្នូ បានជំរុញឱ្យ រដ្ឋាភិបាលកម្ពុជា បើកការស៊ើបអង្កេត ករណីនេះធ្វើឱ្យប្រាកដថា ករណីឃាតកម្ម លើអ្នកកាសែតមួយនេះ គឺមិនអាច ប្រព្រឹត្តដោយមានការផ្តន្ទាទោសឡើយ និងត្រូវចាត់វិធានការជាក់ស្តែងដើម្បី បញ្ចប់អំពើហិង្សាលើអ្នកសារព័ត៌មាន។

របាយការណ៍របស់សម្ព័ន្ធអ្នក សារព័ត៌មានខេមបូចា ឃ្លាំមើលប្រចាំ ត្រីមាសស្តីពីស្ថានភាពអ្នកសារព័ត៌មាន នៅកម្ពុជា ចាប់ពីខែមេសា ដល់ខែមិថុនា ឆ្នាំ២០២៤ ឱ្យដឹងថា ការយាយីលើអ្នក សារព័ត៌មានមានចំនួន ៧ករណី ប៉ះពាល់ ដល់អ្នកសារព័ត៌មាន ១១នាក់។ រីឯការ យាយីតាមប្រព័ន្ធតុលាការមាន ៦ករណី ដោយមានអ្នកសារព័ត៌មាន ១០នាក់ ត្រូវបានកោះហៅទៅសាកសួរ ឃុំខ្លួន និងផ្តន្ទាទោស ដែលធ្វើឡើងដោយ នគរបាល កងរាជអាវុធហត្ថ និងអាជ្ញាធរ មូលដ្ឋាន៕

# អាហារនេះញ៉ាំក្នុងពេលព្រឹក ក្រពះនឹងងាយឈឺណាស់

ខាងក្រោមនេះ យើងខ្ញុំនឹងបង្ហាញ អ្នកពីអាហារពេលព្រឹកដែលអ្នកមិនគួរ ពិសារច្រើនឡើយ។ តើមានអ្វីខ្លះទៅ?

ឆាខ្ទៃ មិនត្រឹមតែធ្វើឲ្យក្រពះងាយ របួសទេ ថែមទាំងធ្វើឲ្យរាងកាយមិន អាចស្រូលយកសារធាតុចិញ្ចឹមបាន គ្រប់គ្រាន់ឡើយ។ ក្រៅពីឆាខ្ទៃ អ្នកក៏ មិនគួរពិសារហាំប៊ឺហ្គ័រ ស្លាបមាន់បំពង ធ្វើជាអាហារពេលព្រឹកផងដែរ ព្រោះវា អាចធ្វើឲ្យសុខភាពអ្នកងាយប្រឈមនឹង គ្រោះថ្នាក់ណាស់ ថែមទាំងធ្វើឲ្យក្រពះ ពិបាករំលាយផងដែរ។

ពេលព្រឹក ជាពេលដែលពោះអ្នក កំពុងតែទទេរ ក្រោយពេលដែលអ្នកញ៉ាំ អាហារដែលហិរនឹងធ្វើឲ្យក្រពះអ្នករបួស ជាខ្លាំង ដោយអាចធ្វើឲ្យអ្នកឈឺក្រពះ




បាន បើធ្ងន់ធ្ងរនឹងអាចក្លាយជាមហារីក ក្រពះក៏មានដែរ។

ក្នុងពេលព្រឹក បើអ្នកញ៉ាំតែបបរស សុទ្ធ ក៏មិនអាចផ្តល់សារធាតុចិញ្ចឹម និង ប្រូតេអ៊ីនដល់រាងកាយបានគ្រប់គ្រាន់ ផងដែរ ថែមទាំងធ្វើឲ្យអ្នកងាយឃ្លាន ទៀតផង។ ដូចនេះ អ្នកមិនគួរពិសារ ច្រើននោះឡើយ។

អាហារដែលសល់ពីយប់ ក៏មិនគួរ យកមកធ្វើជាអាហារពេលព្រឹកដែរ ព្រោះ នៅពេលដែលអ្នកកម្តៅកាន់តែច្រើន វីតាមីនក្នុងនោះនឹងកាន់តែបាត់បង់ ដោយមិនអាចផ្គត់ផ្គង់សារធាតុចិញ្ចឹម ដល់រាងកាយអ្នកបានគ្រប់គ្រាន់នោះ ទេ៕

# អ្នកឃ្លាំមើលជំរុញឱ្យរដ្ឋាភិបាលលើកស្ទួយសិទ្ធិមនុស្ស ដើម្បីលុបបំបាត់រូបភាពអាក្រក់លើឆាកអន្តរជាតិ

ដកស្រង់ពីCambodia Daily

អ្នកស្រាវជ្រាវខាងការអភិវឌ្ឍផ្ទត់គំនិត លោក សេកសុជាតិ លើកឡើងថា ញត្តិចំហរបស់អង្គការចលនាមាតាធម្មជាតិកម្ពុជាទៅកាន់ពលរដ្ឋខ្មែរ គឺជាសារដាស់តឿនមួយសម្រាប់រដ្ឋាភិបាល ត្រូវកែលម្អលើកស្ទួយ#សិទ្ធិមនុស្សឡើងវិញ ដើម្បីលុបបំបាត់រូបភាពកាន់តែអាក្រក់នៅលើឆាកអន្តរជាតិ។

អ្នកផ្តល់ប្រឹក្សាយោបល់ផ្នែកអភិវឌ្ឍន៍ផ្ទត់គំនិត និងការស្រាវជ្រាវ លោក សេក សុជាតិ ប្រាប់សារព័ត៌មាន The Cambodia Daily នៅថ្ងៃទី១១ ធ្នូ នេះថា ការប្រើវិធានការរឹតត្បិតលើសកម្មជនបរិស្ថាន និងសកម្មជនដទៃទៀតដោយការចាប់ចងដើម្បីបំបិទសំឡេងរបស់ពួកគេ មិនមែនជាមធ្យោបាយល្អសម្រាប់រដ្ឋាភិបាលខ្លួនឯងទេ ព្រោះសហគមន៍អន្តរជាតិក៏នឹងដាក់សម្ពាធ ឬទណ្ឌកម្មលើរដ្ឋាភិបាលដូចគ្នា។

លោកថា អ្នកដែលខាតពិតប្រាកដ គឺរដ្ឋាភិបាលខ្លួនឯងប៉ុណ្ណោះ ត្បិតក្រោមវិធានការដ៏តានតឹងនេះ នឹងធ្វើឱ្យបាត់នូវសំឡេងការពារបរិស្ថាន បាត់នូវសំឡេងការពារសិទ្ធិមនុស្ស និងបាត់នូវសំឡេងការពារប្រជាធិបតេយ្យ ជាដើម ខណៈផលប្រយោជន៍ដែលកម្ពុជាធ្លាប់ទទួលបានពីបណ្តាប្រទេសដែលជំរុញឱ្យកម្ពុជាគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនោះ ក៏ត្រូវបាត់បង់ដូចគ្នាដែរ។

លោក សេក សុជាតិ លើកឡើងថា កង្វល់របស់សហគមន៍អន្តរជាតិកន្លងមក ទាំងការរិះគន់ និងការដាក់ទណ្ឌកម្មណាមួយក៏ដោយ គឺគ្រាន់តែមានបំណងចង់ឱ្យរដ្ឋាភិបាលកម្ពុជាក្លាយជាដៃគូសហការក្នុងការអភិវឌ្ឍ ការការពារសិទ្ធិមនុស្សនិងការការពារលទ្ធិប្រជាធិបតេយ្យ ដែលជាគុណប្រយោជន៍សម្រាប់ពលរដ្ឋខ្មែរប៉ុណ្ណោះ។

លោកបញ្ជាក់ថាអ្នកទោសមនសិការ សកម្មជនសង្គមនានា ជាពិសេសយុវជនបរិស្ថានដែលកំពុងត្រូវបានឃុំខ្លួននាពេលនេះ មានចំណែកគុណសម្បត្តិដ៏ធំធេងក្នុងការការពារធនធានធម្មជាតិរបស់កម្ពុជា ជុំវិញការការពារបរិស្ថានដែលត្រូវបានបំផ្លិចបំផ្លាញក្រោមរូបភាពនៃការអភិវឌ្ឍ និងការវិនិយោគដែលអនុញ្ញាតដោយរដ្ឋាភិបាលរហូតមក។



បាតុកម្មរបស់ក្រុមសកម្មជនបរិស្ថាននៅកម្ពុជា

កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៤ ចលនាមាតាធម្មជាតិកម្ពុជា បានចេញញត្តិចំហមួយទៅកាន់ពលរដ្ឋខ្មែរជុំវិញការការឃុំខ្លួនសកម្មជនបរិស្ថានពីសំណាក់រដ្ឋាភិបាលកម្ពុជា ថា សកម្មជនចលនាមាតាធម្មជាតិ រួមមាន លោក លី ចាន់ដារ៉ាវុត កញ្ញា ភួន កែវរស្មី កញ្ញា ឡុងគន្ធា លោក ថុន រដ្ឋា និងលោក យឹម លាងហ៊ី ត្រូវបានរបបសន្តិភាពឃុំខ្លួនទាំងអយុត្តិធម៌ចាប់ពី ៦ឆ្នាំទៅ ៨ឆ្នាំ ដែលជាអំពើរំលោភសិទ្ធិមនុស្សយ៉ាងសាហាវយង់ឃ្នងបំផុត។

គិតមកទល់នឹងពេលនេះ គឺមានរយៈពេល ១៦១ថ្ងៃហើយ ចាប់តាំងពីពួកគេត្រូវបានសមត្ថកិច្ចចាប់ខ្លួនកាលពីដើមខែកក្កដា មក។

ចលនាមាតាធម្មជាតិ លើកឡើងថា ការដឹកនាំក្រោមរបបសន្តិភាពនៅកម្ពុជាសព្វថ្ងៃនេះ បានប្រែក្លាយកម្ពុជាទៅជារបបមួយជា គុកឥតជញ្ជាំង ទៅហើយ ដែលជារបបសង្កត់សង្កិន ចាប់ចងអ្នកការពារសិទ្ធិមនុស្ស ជាពិសេសយុវជនដែលហ៊ាននិយាយពីបញ្ហាប្រទេសជាតិរបស់ខ្លួន។

ទិន្នន័យសង្គមស៊ីវិល បង្ហាញថា ចាប់តាំងពីអំឡុងខែកក្កដា ឆ្នាំ២០២៤ មក រដ្ឋាភិបាលកម្ពុជាបានចាត់វិធានការក្តៅចាប់ខ្លួនពលរដ្ឋដែលបញ្ចេញមតិរិះគន់ការដឹកនាំរបស់ខ្លួនជាបន្តបន្ទាប់ ទាំងសកម្មជននយោបាយ សកម្មជនសង្គម និងអ្នកសារព័ត៌មាន ជាដើម សូម្បីពលរដ្ឋខ្មែរដែលរស់នៅលើទឹកដីថៃ ក៏ត្រូវមេដឹកនាំបក្សកាន់អំណាច លោក ហ៊ុន សែន បញ្ជាឱ្យចាប់ខ្លួនបញ្ជូនទៅប្រទេសកម្ពុជាវិញដែរ៕

# រំដេង : អាចកំបាំងមាសសម្រាប់ក្រពះដែលមានសុខភាពល្អ និងមានប្រសិទ្ធភាពការពារមហារីក

តើអ្នកធ្លាប់មានអារម្មណ៍មិនស្រួលដោយសារតែឈឺពោះ និងក្រហាយទ្រូងជាប្រចាំទេ? រំដេង ជាគ្រឿងទេសដែលធ្លាប់ស្គាល់នៅក្នុងផ្ទះបាយរបស់គ្រួសារគ្រប់រូបអាចជាដំណោះស្រាយដ៏សាមញ្ញ ប៉ុន្តែមានប្រសិទ្ធភាពចំពោះបញ្ហានេះ។

ឱសថដ៏មានតម្លៃនាំមកនូវអត្ថប្រយោជន៍សុខភាពជាច្រើន

រំដេង មិនត្រឹមតែជាគ្រឿងទេសដែលធ្លាប់ស្គាល់នៅក្នុងមុខម្ហូបប៉ុណ្ណោះទេ ប៉ុន្តែក៏ជាឱសថដ៏មានតម្លៃដែលមានអត្ថប្រយោជន៍ជាច្រើនសម្រាប់សុខភាពផងដែរ។



សារធាតុប្រឆាំងអុកស៊ីតកម្ម៖ រំដេង មានសមាសធាតុប្រឆាំងអុកស៊ីតកម្មជាច្រើន ដែលជួយការពាររាងកាយពីភ្នាក់ងារបង្កគ្រោះថ្នាក់ និងការឆ្លងមេរោគ។

-ជំនួយផ្លូវចិត្ត៖ ការសិក្សាបង្ហាញថា quercetin ដែលជាសារជាតិ flavonoid ត្រូវបានរកឃើញនៅក្នុង រំដេង មានសមត្ថភាពកាត់បន្ថយហានិភ័យនៃជំងឺសរសៃប្រសាទដូចជា Alzheimer′s និង Parkinson′s ។ លើសពីនេះអាស៊ីត gallic មានប្រសិទ្ធភាពប្រឆាំងនឹងការរលាកយ៉ាងខ្លាំង។

-កាត់បន្ថយការឈឺចាប់ និងរលាក៖ រំដេង មានសមត្ថភាពកាត់បន្ថយការឈឺចាប់ និងរលាក ដោយសារឥទ្ធិពលរបស់វាទៅលើផ្លូវគីមីដែលទាក់ទងនឹងជំងឺអូតូអ៊ុយមីន។

ប្រសិទ្ធភាពប្រឆាំងបាក់តេរី៖ ការសិក្សាបង្ហាញថា ប្រេងសំខាន់ៗ រំដេង អាចសម្លាប់បាក់តេរី និងផ្សិត ដោយសារសមាសធាតុ terpinen-4-ol ដែលផ្តល់នូវឥទ្ធិពលប្រឆាំងនឹងបាក់តេរីខ្លាំង។

# កំណើតនគរអច្ឆរិយៈ

## ព្រះថោងចាកចេញនគរកំណើតឥន្ទបត្តបុរី តោងស្បៃនាងនាគចូលស្ថានភុជង្គ



**តពីលេខមុន**

**នគរសាមន្តរាជប្រកាសរើសមេទ័ព**

ថ្ងៃនេះព្រលឹមស្រាងៗឡើង គេឃើញមានអ្នកជិះសេះយ៉ាងលឿនម្នាក់ឆ្ពោះតម្រង់មកគេហដ្ឋានលោកសក្កាសង្គ្រាម។ ពេលមកដល់ ចុះពីលើខ្នងសេះ ឡើងទៅលើផ្ទះ លុតជង្គង់លើកក្លាក់សារមួយជូនលោក។ ពេលលោកបើកមើល សារនោះមានន័យដូចតទៅ៖

-យើងទីប្រឹក្សានគរ សូមសួរសុខទុក្ខលោកសក្កាសង្គ្រាម ដែលបែកគ្នាយូរឆ្នាំហើយ។ ពេលនេះនគរយើងកើតសង្គ្រាមជាមួយនគរភ្នំ។ ខាងកងទ័ពយើងទន់ដៃជាងសត្រូវ មិនអាចធន់ទ្រាំយូរតទៅទៀតបានទេ បើគ្មានកងទ័ពជំនួយ និងមេបញ្ជាការដ៏ស្ទាត់ជំនាញដូចរូបលោកមកដឹកនាំទេនុ៎ះប្រជានុរាស្ត្រនឹងត្រូវខ្មាំងរំលោភជិះជាន់ កាប់សម្លាប់ក្រោមដៃសត្រូវមិនខាន។ ខ្ញុំសង្ឃឹមថាលោកមិនអាចឈរមើលនគរយើងវិនាសទេ ដូច្នេះខ្ញុំសូមអញ្ជើញលោកចូលមករាជធានី ពិគ្រោះយោបល់ និងដឹកនាំកងទ័ពការពារទឹកដី និងប្រជាជនយើង។

ពេលអានសារចប់ លោកសក្កាសង្គ្រាម រកកន្លែងឲ្យនិរសារសម្រាករសៀលបន្តិចលោកហៅភរិយានិងកូនមកពិភាក្សា។ លោកពោលទៅកាន់កូនថា ៖

- ព្រឹកមិញពុកបានទទួលសារ ពីលោកទីប្រឹក្សានគរដែលជាចៅហ្វាយនាយនិងជាមិត្រចាស់របស់ពុក ហៅពុកឲ្យចូលទៅដឹកនាំកងទ័ព ជួយការពារនគរ ព្រោះសត្រូវកំពុងវាយប្រហារ។ កូនប្រុស ! កូនបានរៀនសព្វមុខវិជ្ជាពីពុក ពុកជឿជាក់ថា សមត្ថភាពរបស់កូនពេលនេះ កម្រមានអ្នកណាអាចឈ្នះកូនណាស់។ នេះជាឱកាសល្អសម្រាប់កូនចេញទៅសាងកេរ្តិ៍ឈ្មោះដោយចូលទៅបម្រើកងទ័ពជាតិហើយ។

សក្កាជ័យទទួលធ្វើតាមយោបល់របស់ឪពុក ចូលទៅរៀបចំខោអាវនិងសម្ភារៈចាំបាច់ផ្ទាល់ ខ្លួនហើយបម្រុងនឹងទៅលានាងសេដ្ឋានារីនិងម្ដាយ។ តែពេលទៅដល់មុខផ្ទះនាង ឃើញនាងឈរមានកាន់បង្វេចមួយនៅដៃ រង់ចាំខ្លួនជាស្រេច។ នាងសេដ្ឋានារី ដឹងថាសក្កាជ័យត្រូវចេញដំណើរទៅរាជធានី។ នាងមិននិយាយអ្វីមួយម៉ាត់ឡើយ ចូលទៅរៀបចំបង្វេចធ្វើដំណើរ ហើយលាម្ដាយ ទោះជាអ្នកណាឃាត់យ៉ាងណាក៏នាងមិនស្ដាប់ទាំងអស់។ លោកសក្កាសង្គ្រាមនិងភរិយា ឲ្យពរជ័យមង្គលដល់កូនទាំងពីរ ហើយប្រគល់សំបុត្រផ្ដាំផ្ញើមួយច្បាប់ ឲ្យកូនយកទៅជូនលោកទីប្រឹក្សានគរ។

ពិធីជ្រើសរើសមេបញ្ជាការកងទ័ព បានចាប់ផ្ដើមហើយ វិញ្ញាសាប្រឡងប្រជែងមាន សិល្បវិជ្ជាការ មន្តអាគមគាថា ទ្រឹស្តីរៀបក្បួនសឹករបៀបបញ្ជាកងទ័ពវាយប្រហារសត្រូវក្នុងសមរភូមិ ក្បាច់គុនគ្រប់ប្រភេទជិះសេះបាញ់ព្រួញ។ នៅទីបំផុតអ្នកមានថ្វីដៃឆ្លងផុតវិញ្ញា-សារជម្រើសទាំងនេះ ត្រូវប្រកួតផ្ដាច់ព្រ័តជាមួយជើងឯកចាស់ៗទៀត។

សក្កាជ័យបានបង្ហាញនូវភាពក្លាហាន និងទេពកោសល្យកំពូលផ្ដួលគូប្រយុទ្ធម្ដងមួយៗ គ្មានអ្នកណាអាចទប់ទល់បានឡើយ។ ផ្នែកវិញ្ញាសាសំណួរលើទ្រឹស្តី រៀបក្បួនទ័ព និងក្បួនបញ្ជាកងទ័ពវាយលុកសត្រូវក្នុងសមរភូមិ សក្កាជ័យស្ទូត្រចេះចាំទាំងអស់។ នៅទីបំផុតគ្រប់មេប្រយោគប្រកាសលទ្ធផល ទទួលស្គាល់សក្កាជ័យជាជើងឯក ទាំងប្រាជ្ញាឈ្លាសវៃ ទាំងសេចក្ដីក្លាហាន។ លោកទីប្រឹក្សាឡើងវេទិកា ប្រកាសជាឱឡារិកតែងតាំងសក្កាជ័យក្នុងមុខតំណែងអគ្គមេបញ្ជាការកងទ័ព ធ្វើឲ្យមេទ័ពជើងចាស់ជាច្រើនមិនពេញចិត្តព្រោះគិតថាខ្លួនបម្រើកងទ័ពជាយូរណាស់មកហើយ មានស្នាដៃរាប់មិនអស់ឥឡូវត្រូវមកនៅក្រោមបង្គាប់ក្មេងម្នាក់មិនទាន់ជ្រុះពន្លៃពីក្បាលផង។ ដោយស្ថានភាពបន្ទាន់គ្មានពេលរៀបចំច្រើន លោកទីប្រឹក្សាកោះហៅសក្កាជ័យមកទទួលបញ្ជា ចេញកងទ័ពប្រតិបត្តិការសឹក។ កងទ័ពនិងមេបញ្ជាការភាគច្រើន មិនស្ដាប់បង្គាប់ ដោយគ្មានជំនឿចិត្ត លើអគ្គមេបញ្ជាការក្មេងវ័យនេះទេ។ ពួកគេទទួលបញ្ជាដោយខ្ជីខ្ជាធ្វើឲ្យកងទ័ពខ្វះវិន័យរប៉ាត់រប៉ាយ។ បេសកកម្មលើកដំបូងត្រូវបរាជ័យយ៉ាងជូរចត់។ នៅចំពោះមុខស្ថានការណ៍របៀបនេះ សក្កាជ័យអស់សង្ឃឹម គិតថាមិនអាចប្រយុទ្ធតទៅទៀតបានទេអង្គុយក្ដោបក្បាលច្រត់កែងដៃលើតុនៅកណ្ដាលពន្លាមេទ័ព សេដ្ឋានារីចូលមកដល់ឃើញសភាពបែបនេះ នាងខ្លោចចិត្តអាណិតប្រុសដែលនាងស្រឡាញ់ រកថ្លែងមិនបាន។ នាងយល់ថា បានជាធ្លាក់ដល់ដំណាក់កាលនេះ ព្រោះសក្កាជ័យចិត្តទន់ មានសេចក្ដីអាណិតអាសូរច្រើនពេក។ នាងនឹកឃើញមធ្យោបាយដោះស្រាយរឿងនេះ នាងចូលទៅសុំជួបលោកទីប្រឹក្សា រ៉ាយរ៉ាប់ប្រាប់សភាពការណ៍ទាំងអស់ក្នុងសមរភូមិ ដែលមេទ័ពនិងពលទាហានមិនស្ដាប់បង្គាប់តាមបញ្ជា។ នាងស្នើសុំដាវអាជ្ញាសឹក មកប្រគល់ឲ្យអគ្គមេបញ្ជាការ នាងកម្លាចិត្តសក្កាជ័យ ឲ្យដាក់បញ្ញត្តិដាច់ខាតលើកងទ័ព បើអ្នកណាមិនស្ដាប់បង្គាប់ ឬទទួលបញ្ជាទាំងខ្ជីខ្ជា ត្រូវអនុវត្តិច្បាប់អាជ្ញាសឹក ប្រហារជីវិតគ្មានយោគយល់។

សង្គ្រាមចេះតែអូសបន្លាយទៅនៅលើគ្រប់សមរភូមិ សក្កាជ័យបានបង្ហាញសេចក្ដីក្លាហានមោះមុត ដោយស្រឡាញ់មាតុភូមិអស់ពីដួងចិត្ត ទេពកោសល្យប៉ូកនិងទ្រឹស្តីសង្គ្រាមខ្ពស់ មេទ័ពជាច្រើនដែលមានចិត្តច្រណែនកាលពីពេលមុននិងមើលងាយសមត្ថភាពអគ្គមេបញ្ជាការក្មេង ពេលនេះបានប្រគល់សេចក្ដីទុកចិត្តទាំងស្រុងនិងទទួលបញ្ជាយ៉ាងស្វាហាប់។ កងទ័ពទាំងមូលគោរពកោតខ្លាច ជឿជាក់លើមេបញ្ជាការរបស់ខ្លួន ប៉ូកនិងក្បួនយុទ្ធសាស្ត្រដែលនាងសេដ្ឋានារីជួយកែលំអផ្ដល់យោបល់ផង ធ្វើអោយក្បួនប្រយុទ្ធមានប្រសិទ្ធភាពឈ្នះលើសត្រូវ។ សក្កាជ័យជិះសេះបរពលពីមុខពីក្រោយកម្លាចិត្តទ័ពឲ្យលែងខ្លាចស្លាប់។ ពេលមានប្រៀបលើគូសត្រូវ សក្កាជ័យមិនភ្លើតភ្លើននឹងជ័យជំនះឡើយផ្ទុយទៅវិញរឹតតែប្រុងប្រយ័ត្ន មិនទុកចំណុចខ្សោយឲ្យសត្រូវវាយឆ្មក់បាន។ ស្ថានភាពសឹកប្រែពីការទប់ទល់ មកការវាយលុកបកទៅលើសត្រូវវិញ។ កិត្តិស័ព្ទសក្កាជ័យល្បីពេញកងទ័ពជាតិ ព្រមទាំងប្រជា

**តទៅទំព័រទី២៣**



តមកពីទំព័រទី ២២

# កំណើតនគរអច្ឆរិយ

រាស្ត្រទាំងមូល។ មេកន្ទ្រាញជ័យមើលឃើញជ័យជំនះ ត្រឡប់មកខាងខ្លួនវិញ ត្រេកអរណាស់ ដឹកនាំកងទ័ពមួយកង ចេញពិនិត្យស្ថានការណ៍ដោយផ្ទាល់។ ស្រាប់តែដោយចៃដន្យអាក្រក់ ជួបកងឈ្លបរបស់សត្រូវ ដែលបង្កប់ខ្លួនក្បែរបន្ទាយ បាញ់ព្រួញស្រោចមកត្រូវដើមទ្រូងលោកស្លាប់មួយរំពេច ពេលឃើញលោកមេកន្ទ្រាញជ័យស្លាប់ កងទ័ពជ្រួលច្របល់បាត់លំនឹង។ ឃើញឱកាសល្អដូច្នេះ កងទ័ពនគរភ្នំវាយគំហុកយ៉ាងខ្លាំង កងទ័ពល្វសាន្តទិសខូចរបៀបរៀបរយបែកខ្ញែក ដកថយរហូតមកដល់មាត់ទ្វារកំពែង ស្រែកហៅឲ្យបើកទ្វារបន្ទាយ។ ឃើញសភាពគ្រោះថ្នាក់ដូច្នេះ សក្តាជ័យគិតថា បើបើកទ្វារបន្ទាយឲ្យពួកទាហានខាងក្រៅចូល កងទ័ពសេះរបស់សត្រូវដែលបោះពួយយ៉ាងលឿនតាមពីក្រោយមក នឹងចូលដល់ក្នុងបន្ទាយ វាយបំបែកបន្ទាយបានយ៉ាងងាយ។ តែបើមិនបើកទ្វារ ពួកពលទាំងប៉ុន្មាននៅខាងក្រៅ ដែលកំពុងបាត់សណ្តាប់ធ្នាប់ នឹងត្រូវសត្រូវសម្លាប់អស់គ្មានសល់។ ពេលអាសន្នធំដូច្នេះ សក្តាជ័យសម្រេចចិត្តភ្លាមៗ ប្រមូលកងទ័ពដែលសេសសល់ទាំងអស់ បើកទ្វារបន្ទាយចេញក្រៅ ទុកតែកងបាញ់ព្រួញឲ្យឡើងទៅលើកំពែង ទុកឲ្យលោកទីប្រឹក្សានិងនាងនារីត្រួតត្រា។ ពេលចេញមកដល់ក្រៅបន្ទាយភ្លាម សក្តាជ័យស្រែកបញ្ជាឲ្យកងទ័ពដែលកំពុងបែកខ្ញែក ប្រមូលគ្នាចែកជាពីរញែកទៅសងខាង។ ចំណែកខ្លួនឯងនិងនាយទាហានដែលមានថ្វីដៃ នាំមុខទ័ពជិះសេះបោះពួយសម្រុក ពុះចំពាក់កណ្តាលទ័ពសេះរបស់ខ្មាំងឲ្យខ្សោយកម្លាំង ហើយបញ្ជាឲ្យកងទ័ព ដែលញែកចេញជាពីរសងខាងបន្ទាយ វាយបកខ្ទប់សត្រូវ។ ចំណែកទ័ពព្រួញលើបន្ទាយបាញ់ស្រោចមកទៀត។ កងទ័ពនគរភ្នំខូចចលនា ស្លាប់និងរបួសអស់ជាច្រើន ដកថយទៅវិញអស់។ កងទ័ពល្វសាន្តទិស ទោះជាស្រោចស្រង់ស្ថានការណ៍សឹក ផុតពីភាពអាសន្នមែន តែបាត់បង់មេទ័ព និងពលទាហានយ៉ាងច្រើន។ សក្តាជ័យនាំទ័ពចូលបន្ទាយវិញ រៀបចំបញ្ចុះសពលោកមេកន្ទ្រាញជ័យ។ លោកទីប្រឹក្សាកោះប្រជុំនាម៉ឺន និងមេទ័ពទាំងឡាយ ពិភាក្សាសម្រេចតែងតាំងសក្តាជ័យ ជាមេដឹកនាំនគរសាមន្តរាជទាំងមូល។

**ព្រះនាងនាគសោមាភគវតីនៃនគរគោកធ្លក**

**ជួបរាជបុត្រសក្តាជ័យ មេទ័ពនៃនគរសាមន្តរាជ**

ព្រះចៅអទិច្ចវង្សាទ្រង់ព្រួយព្រះទ័យណាស់ នៅចំពោះមុខស្ថានការណ៍សឹកបែបនេះ ទ្រង់សម្រេចព្រះទ័យចេញដឹកនាំកងទ័ព ដោយផ្ទាល់ព្រះអង្គវាយលុកពួកបះបោរឲ្យខាងតែបាន។ ទ្រង់ចេញបញ្ជាឲ្យកេណ្ឌរាស្ត្រ រៀបជាក្បួនសឹកមានទ័ពសេះទ័ពដំរីអាវុធយុទ្ធភណ្ឌសម្បើមអស្ចារ្យ ប្តេជ្ញាកំទេចនគរសាមន្តរាជ ឲ្យទៅជាផេះ។ ដំណឹងនេះជ្រាបទៅដល់ព្រះកាណ៌ព្រះអគ្គមហេសីសោមាទេវី។ ទ្រង់វិតក្កខ្លាំងណាស់ រិះរកមធ្យោបាយដើម្បីជួយព្រះស្វាមីយប់នោះ ពេលទ្រង់កំពុងផ្ទុំលើព្រះទែនសយនា ទ្រង់សុបិនឃើញអ្នកសច្ចំ ស្លៀកសពាក់ស ពុកចង្កាសក្បុស ប្រត្យក្សឡើងចំពោះព្រះភ័ក្ត្រ ហើយទូលថា ៖

- មេទ័ពក្មេងនៃនគរល្វសាន្តទិសនោះ គឺជាព្រះរាជបុត្រារបស់ព្រះនាង ញាស់ពីពងសត្វដែលព្រះនាងទុកចោលក្នុងព្រៃ។

ពេលតើនចាកក្រឡាបន្ទំព្រះអគ្គមហេសីទ្រង់ព្រះពិលាបខ្សឹកខ្សួលយ៉ាងខ្លាំង ព្រោះនឹករលឹកបុត្រ។ ទ្រង់មិនដែលភ្លេចទេ បុត្រជាពងសត្វ ដែលទុកចោលក្នុងព្រៃ។ ព្រះនាងរៀបចំព្រះកាយចូលទៅគាល់ព្រះស្វាមី ហើយទូលទ្រង់អំពីសុបិនគ្រប់ប្រការ។ ព្រះបាទអទិច្ចវង្សាទ្រង់ព្រះសណ្តាប់ហើយ ទ្រង់សញ្ជឹងគិតមួយស្របក់មិនចេញព្រះឱស្ឋអ្វីឡើយ។ ព្រះអគ្គមហេសីទូលសុំយាងទៅជួបព្រះរាជបុត្រា។ ព្រះរាជាយល់ព្រមតាមសំណូមពរ ទ្រង់បញ្ជាឲ្យរៀបកងរក្សាអង្គ មួយកងតូច ដោយគ្មានអាវុធនៅដៃ ដង្ហែព្រះនាងឆ្ពោះទៅកាន់បន្ទាយនគរល្វសាន្តទិស។

ព្រលឹមស្រាងៗឡើង ទាហានយាមបន្ទាយនគរល្វសាន្តទិស ឃើញរាជរថទឹមដោយសេះពីរ មានកងការពារមួយកងតូចដៃគ្មានអាវុធ បរសំដៅមកកាន់បន្ទាយខ្លួន។ឆ្ងល់ណាស់ក៏ឡើងទៅរាយការណ៍ ពីហេតុចម្លែកនេះ។ សក្តាជ័យនិងអ្នកមុខអ្នកការទាំងអស់ឈរមើលពីលើកំពែងបន្ទាយ មិនដឹងថាខ្មាំងចង់លេងកលល្បិចអ្វី។ ពេលរាជរថមកដល់មុខទ្វារបន្ទាយ គេឃើញស្ត្រីម្នាក់រាងចំណាស់បន្តិច តែមានសម្រស់ផូរផង់ ប្រកបដោយព្រះអម្ពរពស្ត្រាជាព្រះរាជនី យាងចុះពីរាជរថមានដំណើរល្វតល្វន់តែអង់អាច មានសេនាបាំងក្លស់ថ្វាយនាយសេនាការពារស្រែកប្រកាសឡើងថា ៖

-ព្រះរាជនីសោមាភគវតីអគ្គមហេសីព្រះចៅនគរគោកធ្លកបុរី ស្នើសុំជួបលោកមេទ័ពសក្តាជ័យ។ ឮដូច្នោះសក្តាជ័យនិងមេទ័ពទាំងអស់ពិគ្រោះគ្នា ឃើញថាគ្មានគ្រោះថ្នាក់អ្វីឡើយក៏បញ្ជាឲ្យបើកទ្វារយាងព្រះនាងចូលក្នុងបន្ទាយ។ព្រះនាងយាងគង់លើអាសនៈដែលគេក្រាលថ្វាយ មានព្រះភក្ត្រញញឹមទតចំមករាជបុត្រ ចំហាយធម្មធាតុព្រហ្មវិហារធម៌និងសេចក្តីស្នេហារាជបុត្រា ស្រោចស្រប់មកលើសក្តាជ័យ និងអ្នកឯទៀតដែលមានវត្តមាននៅទីនោះ ហាក់ដូចជាមានអំណាចអាថ៌កំបាំងអ្វីម៉្យាង ធ្វើឲ្យអ្នកទាំងនោះទទួលអារម្មណ៍ត្រជាក់ក្សេមក្សាន្ត ចុះញ៉មចំពោះអានុភាពព្រះមាតា។ សក្តាជ័យប្រឹងប្រមូលអារម្មណ៍តាំងចិត្តមោះមុតឡើង ទូលសួរថា ៖

-ក្រាបទូលព្រះនាងម្ចាស់តើព្រះនាងមានបំណងយ៉ាងណា បានជាយាងមកទីនេះដោយមិនខ្លាចគ្រោះថ្នាក់ដូច្នេះ? ព្រះនាងញញឹមយ៉ាងស្ងប់ស្ងៀម សំឡឹងដោយកែវនេត្រាស្រទន់មើលមកបុត្រា បើកព្រះឱស្ឋមានបន្ទូលថា ៖

-មាតាយាងមកនេះដើម្បីប្រាប់បុត្រថា យើងជាមាតាបង្កើតរបស់បុត្រ ដែលកាលណោះបុត្រកើតមកជាពងសត្វ ហើយបិតាបុត្រទុកក្នុងព្រៃ ដោយមានទ្រាប់កម្រាលស្បៃសារពស្ត្ររូបនាគនៅពីក្រោម។ សម្លេងព្រះនាងរំពងក្រអៅលាយដោយមនោសញ្ចេតនាករុណា សក្តាជ័យស្តាប់ឮហើយ ទទួលអារម្មណ៍ដូចក្រឡាប់ផែនដី ស្ទើរផ្ងារទៅក្រោយ។ ក្នុងចិត្តជឿជាក់ឥតសង្ស័យថា សំដីព្រះនាងស្មោះត្រង់ពិតប្រាកដ តែគ្មានហេតុផលអ្វីជាភស្តុតាង បញ្ជាក់ថាជាការពិតសោះ។ ក្នុងចិត្តរារែកតែមិនហ៊ានប្រកែកថាមិនពិតដែរ។ អង្គប្រជុំនៅជុំវិញស្ងាត់ជ្រាប បរិយាកាសធ្ងន់ពាប់ ម្នាក់ៗស្ទើរតែមិនហ៊ានកម្រើកខ្លួន គ្មាននរណាម្នាក់ហ៊ានបញ្ចេញយោបល់អ្វីឡើយ។ ពេលកន្លងផុតទៅមួយសន្ទុះធំ ទើប

**តទៅលេខក្រោយ**





សូម
ដាក់ពាក្យ
ថ្ងៃនេះ !
សាលារៀនសាធារណៈសហគមន៍
ឆាទ័រនៃទីក្រុងឡូវែល
សាលារៀនឆាទ័រ (LCCPS) គឺជាសាលារៀនសាធារណៈ(រដ្ឋ)ឆាទ័រកំពុងបំរើសេវាអប់រំដល់សិស្សានុសិស្សចំនួន៨១៥រូប ចាប់ពីថ្នាក់មត្តេយ្យបឋមដល់ថ្នាក់ទី៨ ដោយឥតបង់ថ្លៃការសិក្សា ស្ថិតនៅទីប្រជុំជនក្រុងឡូវែលនៃរដ្ឋម៉ាស្សាឈូសិត ។
ថ្ងៃផុតកំណត់ដាក់ពាក្យ
ថ្ងៃទី២៨ ខែកុម្ភៈ ២០២៥
វគ្គផ្សព្វផ្សាយព័ត៌មាន
• ថ្ងៃទី៧ ខែមករា ២០២៥
• ថ្ងៃទី៦ ខែកុម្ភៈ ២០២៥
ថ្ងៃចាប់ឆ្នោត
ថ្ងៃទី៥មីនា២០២៥@៥:៣០ល្ងាច
សូមទំនាក់ទំនងតាមលេខ
(978) 323 - 0800
សាលារៀនឆាទ័រគឺសំរាប់កូនលោកអ្នក ?
• គាំទ្រភាសាអង់គ្លេសELL & តម្រូវការពិសេស
• កម្មវិធីថ្ងៃសិក្សារយៈពេលវែង
• កម្មវិធីប្រកួតកីឡា
• កម្មវិធីអប់រំចំរុះមុខវិជ្ជា
• កម្មវិធីសិស្សពូកែ និងទេពកោសល្យ
• កម្មវិធីមុខវិជ្ជាអប់រំជាច្រើនទៀត !
98.7%
ក្រុមគ្រួសារនិយាយថា សាលារៀនឆាទ័រកំពុងរៀបចំឱ្យកូនៗរបស់ពួកគេទទួលបានជោគជ័យនៅពេលអនាគត់ ។
ភាពជាថ្នាក់ដឹកនាំ | ឧត្តមភាព | ភាពជោគជ័យ | ពហុវប្បធម៌
206 Jackson Street | Lowell | www.lccps.org
LCCPS LOWELL COMMUNITY CHARTER PUBLIC SCHOOL